**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2022, 15:46
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈអមដោយឧបសម្ពន្ធសាធារណៈ ១**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូល**
**សុំឲ្យដាក់សារណាឆាក់ទងនឹងការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Fergal GAYNOR
(បម្រុង)

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ្យ អង្គ

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្តី**
គង់ សំអុន
Anta GUISSÉ

# I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាសុំឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ដែលស្នើសុំឱ្យដាក់សារណា ពាក់ព័ន្ធនឹងការពិនិត្យឡើងវិញទៅលើឯកសារសម្ងាត់ និងសម្ងាត់បំផុតនៅក្នុងសំណុំរឿង ០០២ ("សំណើសុំឱ្យដាក់សារណា")[1] ដែលនឹងធ្វើឡើងនៅពេលខាងមុខ អនុលោមតាមកាតព្វកិច្ចក្នុងមាត្រា ១២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (វិ.លើកទី២) ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ")[2] ក្នុងនាមជាអង្គជំនុំជម្រះចុងក្រោយដែលពិនិត្យលើសំណុំរឿង ០០២។

2. ដូចដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ("អ.ស.ប") បានផ្ដល់ការកត់សម្គាល់ថា "តាមរយៈការងាររបស់ខ្លួន អង្គជំនុំជម្រះកំពុងបង្កើតកំណត់ហេតុតុលាការ ស្ដីពីសម័យកាលខ្មែរក្រហមសម្រាប់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ"[3]។ កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀង អ.វ.ត.ក[4] ចែងច្បាស់ថា អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ("រ.រ.ក") យល់ព្រមគ្នាថា ជាការសំខាន់ដែលធានាថាបណ្ណសាររបស់ អ.វ.ត.ក ត្រូវបានរក្សាទុកដោយអនុលោមតាមបទដ្ឋានអន្តរជាតិ ហើយសាធារណជន "អាចចូលមើលបានយ៉ាងទូលំទូលាយ"[5]។ ដើម្បីសម្រេចតាមគោលដៅនេះ កិច្ចព្រមព្រៀងបន្ថែមតម្រូវឱ្យ អ.វ.ត.ក ថែទាំ រក្សាទុក និងគ្រប់គ្រងបណ្ណសាររបស់ខ្លួនរួមទាំង

---

[1] ឯកសារ F71/1/1 អនុស្សរណៈអន្តរការិយាល័យ៖ "ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ ("សំណើសុំឱ្យដាក់សារណា")។

[2] សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី ២ ធ្វើវិសោធនកម្មនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ និងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ")។ ទោះបីសំណើសុំឱ្យផ្ដល់អំណះអំណាងពឹងផ្អែកទៅលើវិសោធនកម្មលើកទី១ នៃសេចក្ដីណែនាំអនុវត្តក៏ដោយ តែសហព្រះរាជអាជ្ញាសូមយោងក្នុងចម្លើយតបនេះទាំងមូលទៅលើវិសោធនកម្មលើកទី២ ដោយសារមានការយល់ដឹងថា បច្ចុប្បន្នសេចក្ដីណែនាំអនុវត្តនេះគ្របដណ្ដប់ទៅលើកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។

[3] របាយការណ៍របស់អគ្គលេខាធិការ ស្ដីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ មុខងារសេសសល់ ឯកសារ អ.ស.ប លេខ A/75/809 ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ កថាខណ្ឌ ១៦។

[4] កិច្ចព្រមព្រៀងបន្ថែម ទៅលើកិច្ចព្រមព្រៀងរវាងរាជ រ.រ.ក និង អ.ស.ប ទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្ដីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ("កិច្ចព្រមព្រៀងបន្ថែម")។

[5] កិច្ចព្រមព្រៀងបន្ថែម មាត្រា ៣.១។

*ការធ្វើចំណាត់ប្រភេទជាសាធារណៈ* នូវឯកសារ និងសម្ភារនានា ឆ្លើយតបទៅនឹងសំណើសុំចូលពិនិត្យមើលឯកសារ និង ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនពាក់ព័ន្ធនឹង អ.វ.ត.ក[6]។ កិច្ចព្រមព្រៀងបន្ថែមនេះក៏*តម្រូវឱ្យ* អ.វ.ត.ក ត្រូវ “អនុញ្ញាតឱ្យសាធារណជនមានសិទ្ធិចូលមើលបាននូវសំណៅអេឡិចត្រូនិក និងសំណៅជាក្រដាសនៃបណ្ណសារសាធារណៈ”[7]។

3. សិទ្ធិទទួលបានព័ត៌មាន ស្ថិតក្រោមក្របខណ្ឌទូទៅនៃសេរីភាពនៃការបញ្ចេញមតិ។ ដូចដែលនឹងបង្ហាញជូនខាងក្រោម ការអនុញ្ញាតឱ្យសាធារណជនអាចចូលមើលបាននូវកិច្ចដំណើរការនីតិវិធីច្បាប់ឱ្យបានក្នុងកម្រិតអតិបរមា គឺជាការលើកកម្ពស់ការជឿជាក់ក្នុងដំណើរការផ្លូវច្បាប់។ ប៉ុន្តែទោះបីសិទ្ធិទទួលបានព័ត៌មាន និងតម្លាភាពជាវត្ថុបំណងដ៏សំខាន់ក្តី តែវាត្រូវមានតុល្យភាពជាមួយសិទ្ធិ និងផលប្រយោជន៍ផ្សេងទៀត[8]។ សិទ្ធិ និងផលប្រយោជន៍ចម្បងជាងគេគឺការការពារសិទ្ធិរបស់ជនជាប់ចោទ សាក្សី និងជនរងគ្រោះ[9] ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងបន្ថែមស្រាប់[10]។ ចំណុច

---

6 កិច្ចព្រមព្រៀងបន្ថែម មាត្រា ២.១។

7 កិច្ចព្រមព្រៀងបន្ថែម មាត្រា ៣.២។

8 *សូមមើលឧទាហរណ៍* កិច្ចព្រមព្រៀងរវាងរាជ [រ.រ.ក] និង [អ.ស.ប] ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ (“កិច្ចព្រមព្រៀង អ.វ.ត.ក”) មាត្រា ១២(២), ២៣។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៣៣ថ្មី, ៣៤ថ្មី។ វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិ.លើកទី៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង” ឬ “វិធាន”) វិធាន ២១(១)។ សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា ១.២។ សំណុំរឿង ០០១-ឯកសារ **F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៅក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ (“គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទក្នុងសំណុំរឿង ០០១”) កថាខណ្ឌ ៥-៦។

9 *សូមមើលឧទាហរណ៍* សំណុំរឿង ០០៤/១-ឯកសារ **D304/6/4** សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អ.ប.ជ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ (“សេចក្តីសម្រេចរបស់ អ.ប.ជ លើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឡើងវិញ”) កថាខណ្ឌ ២៣។ ឯកសារ **E118/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចំណងជើង “ចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដែលស្នើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង (E118)” ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១។ *រឿងក្តី Yekatom និង Ngaïssona* អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ កថាខណ្ឌ ៨ (ក្នុងការវាយតម្លៃថាឯកសារអ្វីខ្លះដែលត្រូវដាក់ជាសាធារណៈ ចៅក្រមតែម្នាក់បានរក្សាតុល្យភាពរវាងផលប្រយោជន៍ផ្សេងៗគ្នាដែលកំពុងប្រឈម រួមមាន គោលការណ៍នៃភាពសាធារណៈ សុវត្ថិភាព សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត សេចក្តីថ្លៃថ្នូរ និងឯកភាពរបស់ជនរងគ្រោះ និង

នេះរួមមាន ការការពារសម្ភារសម្ងាត់ផ្ទាល់ខ្លួន ដូចជា ព័ត៌មានរសើប ឬព័ត៌មានឯកជន ពាក់ព័ន្ធនឹងបញ្ហាផ្លូវចិត្ត និងផ្លូវកាយ ចម្លើយនានាដែលមានបង្ហាញឈ្មោះ ឬបង្ហាញអត្តសញ្ញាណជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និង ការបង្ហាញព័ត៌មានរសើបផ្សេងទៀត ដែលមាននៅក្នុងចម្លើយនានាដែលទទួលបានតាមរយៈការប្រើប្រាស់ ឬការគំរាមកំហែងអំពីការធ្វើទារុណកម្ម[11]។

4. ដោយគិតដល់ការរក្សាតុល្យភាព សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងសំណើសុំឱ្យដាក់សារណារបស់ អ.ជ.ត.ក។ នៅក្នុងសារណារបស់ខ្លួន សច្ចធារណ៍រក្សាការសម្ងាត់ដែលអនុវត្តនៅក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការបានបញ្ចប់ នៅពេលកិច្ចដំណើរការនីតិវិធីចប់សព្វគ្រប់ ដោយសារលែងមានហានិភ័យទូទៅនៃការប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរទៀតហើយ។ នាពេលនេះ សច្ចាធារណ៍នៃការបង្ហាញជាសាធារណៈអនុវត្តចំពោះសម្ភារទាំងអស់ដែលគ្រប់គ្រងដោយ អ.វ.ត.ក។ នេះជាគោលការណ៍ណែនាំដែលអនុវត្តចំពោះសម្ភារទាំងអស់នៅក្នុងសំណុំរឿង ០០២ លុះត្រាតែការការពារផលប្រយោជន៍ផ្សេងទៀតតម្រូវឱ្យរក្សាទុកនូវ ស្ថានភាពជាសម្ងាត់ ឬសម្ងាត់បំផុត។ ហេតុនេះ សហព្រះរាជអាជ្ញាគាំទ្រដល់ការកោសលុបទៅលើព័ត៌មានសម្ងាត់ក្នុងឯកសារ ជាជាងធ្វើចំណាត់ប្រភេទជាឯកសារសម្ងាត់ទៅលើឯកសារទាំងមូល និងយល់ឃើញថាវាជាប្រយោជន៍នៃកេរដំណែលដ៏រឹងមាំរបស់ អ.វ.ត.ក ដែលថា គួរប្រើប្រាស់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុឱ្យបានច្រើន ក្នុងដំណើរការពិនិត្យឡើងវិញ និងការកោសលុបទៅលើឯកសារទាំងនេះ។

5. ចុងក្រោយ ក្រៅពីការធ្វើចំណាត់ប្រភេទឡើងវិញ សហព្រះរាជអាជ្ញាសូមជំរុញឱ្យ អ.ជ.ត.ក បង្កើតនូវគោលការណ៍មួយដែលគ្រប់គ្រងដល់ការចូលពិនិត្យមើលកំណត់ត្រារបស់ អ.វ.ត.ក[12]។

---

សាក្សី និងសិទ្ធិមានឯកជនភាពរបស់ជនជាប់ចោទ)។

10 កិច្ចព្រមព្រៀងបន្ថែម មាត្រា ២.១ (រៀបរាប់ជាមុខងារសេសសល់គឺ “ផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី”)។

11 ការដាក់ឯកសារទាំងនេះជាសាធារណៈអាចបណ្តាលឱ្យមានព្យសនកម្មជាច្រើន រួមទាំង ស្លាកស្នាមទុយ៌ស ឬវិវាទនៅក្នុងសហគមន៍ (ជាពិសេស ប្រសិនបើឯកសារនោះធ្វើការចោទប្រកាន់ទៅលើអ្នកដទៃពីឥរិយាបថឧក្រិដ្ឋ) ផលវិបាកអវិជ្ជមានទៅលើសមាជិកគ្រួសារដែលមិនបានដឹងពីព្យសនកម្មទាំងនោះ (រួមទាំងកុមារដែលកើតចេញពីការរួមភេទដោយបង្ខំ នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ) និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើចេតនារបស់សាក្សី និងជនរងគ្រោះ (សូម្បីតែនៅតុលាការផ្សេងទៀតក្តី) មិនឱ្យនិយាយដោយស្មោះត្រង់ អំពីបញ្ហាឯកជនស្រដៀងគ្នា ទោះបីមានការធានារក្សាការសម្ងាត់ក៏ដោយ។

12 សហព្រះរាជអាជ្ញាសូមយោងទៅគោលការណ៍នៃការចូលពិនិត្យមើលឯកសារ ដែលនៅជាធរមាន នៅឯយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (IRMCT) តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនសម្រាប់កិច្ចការសេសសល់

ការបង្កើតគោលការណ៍ណែនាំ ដែលរៀបរាប់អំពីយុត្តិកម្មនានាដែលធានាដល់ការចូលពិនិត្យមើល និងគោលបំណងតិចតួច ដែលឯកសារនានាត្រូវបានធ្វើចំណាត់ប្រភេទជាសម្ងាត់ ឬសម្ងាត់បំផុត នៅពេលអនុញ្ញាតឱ្យចូលពិនិត្យមើលនោះ អ.ជ.ត.ក នឹងធានានូវភាពស្របគ្នា និងភាពត្រឹមត្រូវក្នុងការអនុវត្តគោលការណ៍នោះ។ ដើម្បីឱ្យស្របតាមអាណត្តិ និងគោលបំណងរបស់ អ.វ.ត.ក វិធីសាស្ត្ររួមគួរតែរក្សាតុល្យភាពរវាងគោលការណ៍នៃភាពបើកចំហនិងតម្លាភាព ទៅនឹងកាតព្វកិច្ចថែរក្សាផលប្រយោជន៍ផ្នែកសន្តិសុខ និងឯកជនភាពរបស់បុគ្គលដែលមានឈ្មោះនៅក្នុងកំណត់ត្រា អ.វ.ត.ក។

## II. ប្រវត្តិនីតិវិធី

6. សហព្រះរាជអាជ្ញាសូមលើកឡើងនូវប្រវត្តិនីតិវិធីក្នុងសំណុំរឿង ០០២ ដែលពាក់ព័ន្ធ។ នៅពេលសេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឡើងវិញនៅក្នុងសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក ជូនជាព័ត៌មានចំពោះដំណើរការនាពេលបច្ចុប្បន្ននេះ សេចក្តីសម្រេចទាំងនោះនឹងលើកយោងនៅក្នុងអំណះអំណាងនានាដូចខាងក្រោម។

7. នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) បានជូនដំណឹងដល់ភាគីនានាថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ហើយ ជាមួយសំណើសុំបំពេញកិច្ចស៊ើបសួរទាំងអស់ អនុលោមតាមវិធាន ៦៦(១) ដីកាសម្រេចរបស់ ស.ច.ស និង សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ (“អ.ប.ជ”) ត្រូវបានសម្រេចត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០[13]។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ត្រូវបានចេញ[14]។ ស.ច.ស បានកោសលុបឈ្មោះសាក្សីចេញពីសំណៅសាធារណៈ ប៉ុន្តែបានរក្សាទុកភស្តុតាងទាំងអស់ មានឈ្មោះជនរងគ្រោះ (ទាំងអ្នកនៅរស់ និងអ្នកបានទទួលមរណភាព) ដែលមិនបានផ្តល់សក្ខីកម្ម និងសំអាងហេតុ និងសំអាងច្បាប់ទាំងអស់។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អ.ប.ជ បានតម្កល់ដីកា

(“RSCSL”) និងមូលដ្ឋានទិន្នន័យកំណត់ហេតុតុលាការរួម (ICTR, ICTY និង IRMCT) ការណែនាំដល់អ្នកប្រើប្រាស់សម្រាប់ព័ត៌មានលម្អិត។

13 *សូមមើល* ឯកសារ **D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ (“ដីកាដំណោះស្រាយ”) កថាខណ្ឌ ១៣។

14 ឯកសារ **D427** ដីកាដំណោះស្រាយ។

ដំណោះស្រាយ ដោយមានការកែប្រែមួយចំនួន នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[15]។

8. នៅក្នុងសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បានបង្ហាញថា មានឯកសារចំនួន ៥.១០២ និងសម្ភារផ្សេងទៀតត្រូវបានដាក់បង្ហាញនៅចំពោះមុខខ្លួន អនុលោមតាមវិធាន ៨៧(៣) ដែលស្ថិតក្នុងការធ្វើចំណាត់ប្រភេទ "សម្ងាត់" ដោយស្វ័យប្រវត្តិក្នុងអំឡុងពេលកិច្ចស៊ើបសួរ តែបានសម្រេចថា ភាពសម្ងាត់លែងជាការចាំបាច់ទៀតហើយចំពោះព័ត៌មានដែលបានបង្ហាញជាសាធារណៈនៅក្នុងសាលក្រម[16]។ ទោះជាយ៉ាងណាក្ដី អ.ជ.ស.ដ មិនបានធ្វើចំណាត់ប្រភេទជាសាធារណៈនូវឯកសារជាមូលដ្ឋាន ដែលអង្គជំនុំជម្រះបានលើកយកសំអាងនោះទេ[17]។

9. ក្នុងអំឡុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ឯកសារមួយដែលដាក់បង្ហាញក្នុងសវនាការជាសាធារណៈត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈ និងបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការ[18]។ ឯកសារផ្សេងទៀតពុំត្រូវបានធ្វើបែបនោះទេ។ ឧទាហរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ ("WRI") ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ("CPA") មួយចំនួន និងឯកសារផ្សេងទៀតដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេលស៊ើបអង្កេត ក្នុងសំណុំរឿង ០០៣, ០០៤/១, ០០៤/២ និង ០០៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈនូវកំណត់ហេតុស្ដាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដោយសារ

---

[15] **D427/2/12** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។ ឯកសារ **D427/4/14** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។ ឯកសារ **D427/1/26** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

[16] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១") កថាខណ្ឌ ៣៩។

[17] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ជើងទំព័រ ១០៦។

[18] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សាលក្រមសំណុំរឿង ០០២/០២") កថាខណ្ឌ ៣៥។

ឯកសារទាំងនេះជាឯកសារសម្ងាត់ នៅក្នុងសំណុំរឿងដែលកំពុងដំណើរការស៊ើបអង្កេត[19]។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ អ.ជ.ស.ដ បានកត់សម្គាល់ថា ឯកសារចំនួន ១៤.៤៧៦ និងសម្ភារផ្សេងទៀតដែលដាក់នៅចំពោះមុខខ្លួននៅតែ "សម្ងាត់" ដដែល ដោយសារការកំណត់ដោយស្វ័យប្រវត្តិក្នុងអំឡុងពេលស៊ើបសួរ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានសម្រេចថាភាពសម្ងាត់លែងជាការចាំបាច់ទៀតហើយ ចំពោះព័ត៌មានដែលបានបង្ហាញជាសាធារណៈនៅក្នុងសាលក្រម[20]។

10. ក្រោយពេលចេញសាលក្រមក្នុងសំណុំរឿង ០០២/០២ អ.ជ.ស.ដ បានអញ្ជើញភាគីនៃសំណុំរឿង ០០២ អ.ប.ជ និង ស.ច.ស ឱ្យផ្តល់យោបល់ទៅលើការធ្វើចំណាត់ប្រភេទឡើងវិញទៅជាសាធារណៈដែលបានស្នើឡើង ចំពោះឯកសារដែលបានលើកយោងនៅក្នុងសាលក្រម[21]។ ជាការឆ្លើយតបវិញ ខៀវ សំផន បានប្តេជ្ញាអនុវត្តតាម "គោលការណ៍តុលាការបើកចំហ" គាត់មិនបានជំទាស់ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ និងសំណើសុំឱ្យធ្វើចំណាត់ប្រភេទជាសាធារណៈចំពោះសារណាចំនួន១២ ដែលគាត់បានដាក់[22]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") មិនបានជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទជាសាធារណៈនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានក្នុងបញ្ជី និងទម្រង់បែបបទព័ត៌មានបន្ថែម ("SIF") ដែលត្រូវអនុវត្តតាមមាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ ដែល

---

[19] ឯកសារ **E319/35/15/2** អនុស្សរណៈអន្តរការិយាល័យពី ស.ច.ស.អ ផ្ញើជូន អ.ជ.ស.ដ ចំណងជើង "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចំណងជើង "អនុស្សរណៈសុំការបញ្ជាក់បំភ្លឺអំពីអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ E319/35/14/3 – E319/35/15/1") ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ("អនុស្សរណៈរបស់ ស.ច.ស.អ ស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញ") កថាខណ្ឌ ៨-១០។

[20] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤។

[21] ឯកសារ **E467** អនុស្សរណៈរបស់ អ.ជ.ស.ដ ចំណងជើង ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង០០២/០២ ដែលស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ ភ្ជាប់ជាមួយឧបសម្ព័ន្ធចំនួន ៤ គឺ៖ ឯកសារ **E467.1** ឧបសម្ព័ន្ធ ក៖ ភស្តុតាងដែលបានដាក់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២, ឯកសារ **E467.2** ឧបសម្ព័ន្ធ ខ៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណានានាដែលបានដាក់ក្នុងសំណុំរឿង ០០២ ដែលពាក់ព័ន្ធ, ឯកសារ **E467.3** ឧបសម្ព័ន្ធ គ៖ ឯកសារនានាដែលបានដាក់ ឬនៅចំពោះមុខ ក.ស.ច.ស ក្នុងអំឡុងពេលកិច្ចស៊ើបសួរតាមផ្លូវតុលាការ ក្នុងសំណុំរឿង ០០២, ឯកសារ **E467.4** ឧបសម្ព័ន្ធ ឃ៖ ឯកសារនានាពាក់ព័ន្ធនឹងជនរងគ្រោះដែលលែងជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។

[22] ឯកសារ **E467/1** លិខិតពីលោក គង់ សំអុន និង លោកស្រី Anta Guissé ចំណងជើង "មតិយោបល់លើសំណើសុំធ្វើចំណាត់ប្រភេទឯកសារសម្ងាត់ឡើងវិញ" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩។

តម្រូវឲ្យធ្វើការកោសលុបទៅលើព័ត៌មានទំនាក់ទំនងលម្អិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី[23]។ សហមេធាវីនាំមុខក៏បានជំទាស់ផងដែរចំពោះការធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈ នូវឯកសារមួយចំនួនដែលមានព័ត៌មានហិរញ្ញវត្ថុរបស់ភាគីទីបី និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការផ្តល់សំណង។ ចៅក្រម អ.ប.ជ មិនបានជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឡើងវិញទេ លើកលែងតែករណីមួយ៖ ឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនរបស់សាក្សីដែលស្ថិតក្រោមវិធានការការពារ ឬអ្នកដែលបានស្នើសុំវិធានការការពារហើយរង់ចាំការសម្រេច នៅរក្សាជាឯកសារសម្ងាត់ដដែល។ អ.ប.ជ ក៏បានស្នើសុំ អ.ជ.ស.ដ ឲ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើសេចក្តីសម្រេចរបស់ អ.ប.ជ ផ្សេងទៀតដែលសម្ងាត់ ឬកោសលុបសាធារណៈ នៅក្នុងសំណុំរឿង ០០២ មកជាឯកសារសាធារណៈ ហើយឧបសម្ព័ន្ធដែលមានឯកសារចំនួន ១០៦ ដែលពួកគេស្នើសុំឲ្យធ្វើចំណាត់ប្រភេទឡើងវិញ ស្ថិតក្រោមវិធានការការពារនៅឡើយ[24]។

11. បន្ទាប់ពីបានស្តាប់អំណះអំណាងពីភាគីមានផលប្រយោជន៍ទាំងនោះ អ.ជ.ស.ដ បានធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈ[25] នូវឯកសាររាប់ពាន់ ដូចជា៖ ១) ភ័ស្តុតាងដែលបានដាក់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២[26] ២) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណានានាដែលបានដាក់ក្នុងសំណុំរឿង ០០២ ដែលពាក់ព័ន្ធ[27] ៣) ឯកសារនានាដែលបានដាក់ ឬនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")

---

[23] ឯកសារ **E467/2** មតិយោបល់ និងការជំទាស់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ឯកសារសម្ងាត់នៅក្នុងសំណុំរឿង ០០២/០២ ដែលស្នើសុំឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញ ជាឯកសារសាធារណៈ" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩។

[24] ឯកសារ **E467/5** អនុស្សរណៈអន្តរការិយាល័យពីចៅក្រម អ.ប.ជ ផ្ញើជូនចៅក្រម អ.ជ.ស.ដ ចំណងជើង "ចម្លើយតបចំពោះអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "សំណើចំណាត់ថ្នាក់ប្រភេទឯកសារសម្ងាត់នៅក្នុងសេចក្តីសម្រេចសំណុំរឿង ០០២/០២ ទៅជាសាធារណៈ"" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩។

[25] ឯកសា **E467/6** ដីកាបង្គាប់ធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារក្នុងសំណុំរឿងឲ្យទៅជាសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។

[26] ឯកសារ **E467/6.1** ឧបសម្ព័ន្ធ ១៖ ភ័ស្តុតាងដែលបានដាក់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។

[27] ឯកសារ **E467/6.2** ឧបសម្ព័ន្ធ ២៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណានានាដែលបានដាក់ក្នុងសំណុំរឿង ០០២ ដែលពាក់ព័ន្ធ។

ក្នុងអំឡុងពេលកិច្ចស៊ើបសួរតាមផ្លូវតុលាការ ក្នុងសំណុំរឿង ០០២[28] និង ៤) ឯកសារនានាពាក់ព័ន្ធនឹងជនរងគ្រោះដែលលែងជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២[29]។ អង្គជំនុំជម្រះពន្យារពេលរង់ចាំឱ្យ អ.ជ.ត.ក ចេញសេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឡើងវិញទៅលើ CPA និង SIF ដែលតម្រូវឱ្យមានការពិនិត្យឡើងវិញសម្រាប់ធ្វើការកោសលុប[30] និងសារណាចំនួន ១២ របស់ ខៀវ សំផន បានស្នើសុំ។ អ.ជ.ស.ដ ក៏បានស្នើសុំឱ្យ អ.ប.ជ ពិនិត្យឡើងវិញទៅលើ WRI រាប់រយទៀត[31] និងសេចក្តីសម្រេចនានាដែលភ្ជាប់ជាមួយអនុស្សរណៈរបស់ខ្លួន និងពាក់ព័ន្ធនឹងវិធានការការពារដែលបានអនុវត្ត ក្នុងសំណុំរឿង ០០៣ និង ០០៤/២ និងជូនដំណឹងដល់ អ.ជ.ត.ក ពីភាពចាំបាច់នៃការកោសលុប និងភាពចាំបាច់ក្នុងការរក្សាចំណាត់ប្រភេទឯកសារសម្ងាត់។ តាមការយល់ដឹងរបស់សហព្រះរាជអាជ្ញា អ.ប.ជ មិនបានធ្វើការពិនិត្យឡើងវិញបែបនេះទេ ហើយឯកសារទាំងនោះនៅតែសម្ងាត់ដដែល។

12. នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ចៅក្រម អ.ប.ជ បានធ្វើអនុស្សរណៈអន្តរការិយាល័យមួយជូនចៅក្រម អ.ជ.ត.ក ដោយផ្តល់អនុសាសន៍ធ្វើចំណាត់ប្រភេទឡើងវិញទៅលើសេចក្តីសម្រេច និងដីកាសម្រេចសម្ងាត់របស់ អ.ប.ជ ចំនួន ១៥១ សេចក្តីសម្រេច និងដីកាសម្រេចសម្ងាត់របស់ ស.ច.ស ចំនួន ៣៨៧ សេចក្តីសម្រេចរបស់ អ.ប.ជ ដែលបានធ្វើការកោសលុបចំនួន ១៧ និងសេចក្តីសម្រេច និងដីកាសម្រេចរបស់ ស.ច.ស ដែលធ្វើការកោសលុបជាសាធារណៈចំនួន ៨ នៅក្នុងសំណុំរឿង ០០២។ អ.ប.ជ បានអញ្ជើញ អ.ជ.ត.ក ឱ្យផ្តល់មតិយោបល់ពីភាពចាំបាច់បន្តរក្សាការសម្ងាត់នៃឯកសារទាំងនេះ នៅដំណាក់កាលនេះនៃសំណុំរឿង ០០២ និងបានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឯកសារទាំងនេះជាសាធារណៈ ដោយមានករណីលើកលែងថា ឈ្មោះ និងព័ត៌មាន

[28] ឯកសារ **E467/6.3** ឧបសម្ព័ន្ធ ៣៖ ឯកសារនានាដែលបានដាក់ ឬនៅចំពោះមុខ ក.ស.ច.ស ក្នុងអំឡុងពេលកិច្ចស៊ើបសួរតាមផ្លូវតុលាការ ក្នុងសំណុំរឿង ០០២ ("ការដកចំណាត់ថ្នាក់សំណុំឯកសារដោយ ក.ស.ច.ស")។

[29] ឯកសារ **E467/6.4** ឧបសម្ព័ន្ធ ៤៖ ឯកសារនានាពាក់ព័ន្ធនឹងជនរងគ្រោះដែលលែងជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។

[30] ឯកសារ **E467/6.5** ឧបសម្ព័ន្ធ ៥៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងព័ត៌មានបន្ថែមដែលតម្រូវឱ្យមានការពិនិត្យឡើងវិញសម្រាប់ធ្វើការកោសលុប មុនពេលធ្វើចំណាត់ប្រភេទឡើងវិញ។

[31] ឯកសារ **E467/6.6** ឧបសម្ព័ន្ធ ៦៖ កំណត់ហេតុស្តាប់ចម្លើយដែលតម្រូវឱ្យមានការពិនិត្យឡើងវិញសម្រាប់ធ្វើការកោសលុប មុនពេលធ្វើចំណាត់ប្រភេទឡើងវិញ។

ផ្ទាល់ខ្លួនរបស់សាក្សីដែលស្ថិតក្រោមវិធានការការពារ ឬអ្នកដែលបានស្នើសុំវិធានការការពារហើយរង់ចាំការសម្រេច នៅរក្សាជាសម្ងាត់ដដែល[32]។

13. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ដោយយល់ច្បាស់ពីសារសំខាន់ដ៏ធំធេងនៃការធ្វើចំណាត់ប្រភេទឡើងវិញ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពចាំបាច់ដើម្បីឲ្យ អ.វ.ត.ក មាន "ផលវិជ្ជមានពិតប្រាកដ និងជាយូរអង្វែង" សហមេធាវីនាំមុខបានដាក់សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញ ទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី[33]។ ដោយលើកឡើងនូវសារសំខាន់ចំពោះកូនក្តីរបស់ខ្លួនដែលថា ព័ត៌មានឯកជនបែបរសើបដែលមាននៅក្នុងសំណុំរឿងមិនគួរបញ្ចេញជាសាធារណៈនោះ សហមេធាវីនាំមុខបានរៀបចំអនុសាសន៍មួយចំនួន សម្រាប់ដោះស្រាយចំពោះសម្ភារដើមបណ្តឹងរដ្ឋប្បវេណីរួមមាន ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ("VIF") ទម្រង់បែបបទព័ត៌មានបន្ថែម ("SIF"), WRI, កិច្ចសម្ភាសន៍របស់ DC-Cam របាយការណ៍របស់អង្គភាពគាំពារជនរងគ្រោះ ("VSS") លិខិតផ្ទេរសិទ្ធិដោយអាណត្តិ និងឯកសារពាក់ព័ន្ធនឹងសំណើបន្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី (រួមគ្នាហៅថា "សម្ភារដើមបណ្តឹងរដ្ឋប្បវេណី")។ ពួកគេលើកឡើងថា ទោះបីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញជាសាធារណៈ និងមិនចាំបាច់ធ្វើការកោសលុបក្តី តែព័ត៌មានឯកជន និង/ឬ រសើបនានាបង្កការព្រួយបារម្ភ និងមិនសក្តិសមនឹងបង្ហាញជាសាធារណៈ ដូចជា[34]៖ ១) ព័ត៌មានទំនាក់ទំនងលម្អិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឧទា. លេខទូរស័ព្ទ អាសយដ្ឋាន អាសយដ្ឋានអ៊ីមែល) ច្បាប់ថតចម្លងនៃឯកសារអត្តសញ្ញាណផ្ទាល់ខ្លួន (រួមទាំងរូបថត) និង/ឬលេខអត្តសញ្ញាណ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងព័ត៌មានលម្អិតអំពីសមាជិកគ្រួសារ[35] ២) ព័ត៌មានកំណត់អត្តសញ្ញាណ ដើមបណ្តឹងរដ្ឋប្បវេណី និងភាគីទីបីដែលជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ[36] ៣) ព័ត៌មានវេជ្ជសាស្ត្រផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្ប

---

[32] ឯកសារ F67 អនុស្សរណៈអន្តរជាតិការិយាល័យពីចៅក្រម អ.ប.ជ ផ្ញើជូនចៅក្រម អ.ជ.ត.ក ចំណងជើង "ឯកសារសម្ងាត់ និងឯកសារកោសលុបជាសាធារណៈ នៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានស្នើឲ្យចាត់ចំណាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ("អនុស្សរណៈ អ.ប.ជ ខែឧសភា ឆ្នាំ២០១១ ស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញ")។

[33] ឯកសារ F71 សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញ ទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ("សំណើរបស់សហមេធាវីនាំមុខសុំការសម្រេច") ដកស្រង់ត្រង់កថាខណ្ឌ ២។

[34] ឯកសារ F71 សំណើរបស់ សហមេធាវីនាំមុខ សុំការសម្រេច កថាខណ្ឌ ៣៧។

[35] ឯកសារ F71 សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ២៧-២៨, ៣៨, ៦៣, ៦៨។

[36] ឯកសារ F71 សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៣៩, ៤៨, ៦៤, ៦៨។

វេណី[37] ៤) បទពិសោធន៍ និងទស្សនៈស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ដើមបណ្តឹងរដ្ឋប្បវេណី[38] ៥) សម្ភារដែលទទួលបានតាមរយៈទារុណកម្ម រួមទាំងចម្លើយសារភាព និងប្រវត្តិរូប[39] និង ៦) ការកំណត់ឈ្មោះចារីដែលត្រូវបានសង្ស័យ[40]។

14. ដោយហេតុថា សម្ភារដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនត្រូវបានដាក់ជូន អ.វ.ត.ក ដោយរំពឹងថា នឹងត្រូវបានរក្សាជាការសម្ងាត់នោះ សហមេធាវីនាំមុខពិចារណាឃើញថា គោលការណ៍នៃការព្រមព្រៀងដោយទទួលបានព័ត៌មានគ្រប់គ្រាន់ គួរអនុវត្តទៅលើការផ្សព្វផ្សាយនូវសម្ភារទាំងនោះ លើកលែងតែសម្ភារដែលគ្របដណ្តប់ទៅលើកម្មវត្ថុដែលបានដោះស្រាយ នៅក្នុងសក្ខីកម្មជាសាធារណៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ នៅពេលដែលវាត្រូវបានជំទាស់នៅក្នុងកិច្ចដំណើរការនីតិវិធី ហើយគឺជាសម្ភារនៃបញ្ហាមួយដែលត្រូវបានដោះស្រាយនៅក្នុងសាលក្រម/សាលដីការបស់តុលាការ[41]។ សហមេធាវីនាំមុខបានផ្តល់អនុសាសន៍នានាដូចជា៖ ១) សម្ភារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងភ័ស្តុតាង (និងត្រូវបានផ្តល់លេខសម្គាល់ E3 នៅក្នុងសំណុំរឿង ០០២) ត្រូវបានសន្មតថាឯកសារសាធារណៈ ដោយមានការកោសលុបនូវព័ត៌មានទំនាក់ទំនងលម្អិត និងព័ត៌មានរសើបដែលបានលើកឡើងខាងលើ[42] និង ២) នៅពេលដែលសម្ភារដើមបណ្តឹងរដ្ឋប្បវេណីមិនស្ថិតក្នុងភ័ស្តុតាង ពុំមានការសន្មតថាឯកសារសាធារណៈនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ ហើយឯកសារទាំងនោះគួរចាត់ទុកជាសាធារណៈ ដោយអនុវត្តគោលការណ៍នៃការព្រមព្រៀងដោយទទួលបានព័ត៌

---

[37] ឯកសារ **F71** សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៤០, ៤៨។

[38] ឯកសារ **F71** សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៤១។

[39] ឯកសារ **F71** សំណើរបស់សហមេធាវីនាំមុខ សុំការសម្រេច កថាខណ្ឌ ៤២ *សូមមើលផងដែរ* កថាខណ្ឌ ១៦។

[40] ឯកសារ **F71** សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៤៣។

[41] ឯកសារ **F71** សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៤៤-៤៦, ៦១។

[42] ឯកសារ **F71** សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៥៤-៦១, ៦៩ *ដកស្រង់* សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា ៤(ឃ), ៥.១(ង), ៦(ខ), ៧.៤, ៩.២ រួមគ្នាជាមួយយុត្តិសាស្ត្ររបស់ អ.ជ.ស.ដ ដែល (ក) ភ័ស្តុតាងពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តទៅលើតតិយជន គួរត្រូវបានស្តាប់សក្ខីកម្មក្នុងសវនាការអសាធារណៈ (ជើងទំព័រ ៨៥), (ខ) ការបង្ហាញព័ត៌មានលម្អិតផ្ទាល់ខ្លួនពាក់ព័ន្ធនឹងសាក្សីម្នាក់ដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរគួរត្រូវបានកោសលុប (ជើងទំព័រ ៨៦) និង (គ) អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានការពារ នៅពេលដាក់បង្ហាញ វាអាចបង្កហានិភ័យដល់សុខភាពផ្លូវចិត្ត និងចិត្តសាស្ត្ររបស់ពួកគេ (ជើងទំព័រ ៨៧)។

មានគ្រប់គ្រាន់[43]។ ស.ព.អ បានឆ្លើយតបគាំទ្រសំណើរបស់សហមេធាវីនាំមុខ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១[44]។

15. នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ អ.ជ.ត.ក បានដាក់សំណើរបស់ខ្លួនសុំឱ្យដាក់សារណា។ ជាការឆ្លើយតប នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ចៅក្រម អ.ប.ជ បានបញ្ជាក់នូវការយល់ឃើញនានាដែលបានលើកឡើងនៅក្នុងអនុស្សរណៈរបស់ខ្លួនកាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១[45]។

## III. ច្បាប់ជាធរមាន

## ការសម្ងាត់នៃកិច្ចស៊ើបសួរ

16. វិធាន ២១(១) "គោលការណ៍ជាសារវន្ត" ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង *កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព* ដោយគិតដល់*លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ដូចមានចែងក្នុងច្បាប់ ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖ [...] គ- អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយ*សិទ្ធិរបស់ជនរងគ្រោះ*ត្រូវបាន*ការពារ*ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី។[46]

---

[43] ឯកសារ F71 សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៧០-៧៥។

[44] ឯកសារ F71/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញ ទៅលើឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១។

[45] ឯកសារ F71/1/1/1 អនុស្សរណៈអន្តរការិយាល័យពីចៅក្រម អ.ប.ជ ផ្ញើជូនចៅក្រម អ.ជ.ត.ក ចំណងជើង "ចម្លើយតបទៅនឹង "ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ("អនុស្សរណៈ អ.ប.ជ ខែសីហា ឆ្នាំ២០២២ ស្ដីពីការធ្វើចំណាត់ប្រភេទឡើងវិញ")។

[46] វិធាន ២១ (គូសបញ្ជាក់បន្ថែម)។

17. វិធាន ៥៤ កំណត់ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា គឺជាឯកសារសម្ងាត់[47] ហើយ វិធាន ៥៦(១) ចែងថា "ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវ*ធ្វើឡើង*ជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែល*ចូលរួមក្នុង*ការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់"[48]។

18. មាត្រា ១.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ប្រភេទបញ្ជាក់ថា៖

> គោលការណ៍ណែនាំឲ្យមានសេចក្ដីណែនាំអនុវត្តនេះ គឺជាតម្រូវការទាមទារឲ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរ្ដិ៍ដំណែល[49]។

19. មាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ចំណាត់ប្រភេទ ចែងថា លើកលែងតែមានចំណាត់ប្រភេទផ្សេងពីនេះ ដោយសេចក្ដីសម្រេចរបស់តុលាការ ឯកសារខាងក្រោមគឺជាឯកសារសម្ងាត់៖

ក. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។

ខ. អនុលោមតាមមាត្រា ៤ សំណុំឯកសារដែលទទួលបាន និងភ័ស្តុតាងដែលផ្ដល់ឲ្យនៅដំណាក់កាលស៊ើបអង្កេតរបស់តុលាការ។

គ. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ការថតសំឡេង/រូបភាពនៃការធ្វើសម្ភាសន៍ និងសកម្មភាពស៊ើបអង្កេតផ្សេងៗ ដែលបានធ្វើឡើងដោយ ស.ច.ស ឬអ្នកដែលទទួលបានសិទ្ធិឲ្យស៊ើបសួរជំនួស។

ឃ. បណ្ដឹងរបស់ជនរងគ្រោះ។

---

[47] វិធាន ៥៤។

[48] វិធាន ៥៦(១) (គូសបញ្ជាក់បន្ថែម)។

[49] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ចំណាត់ប្រភេទ មាត្រា ១.២។

ង. អត្តសញ្ញាណ អាសយដ្ឋានលំអិតរបស់ជនរងគ្រោះ ដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី (ដែលរួមមានពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)។

ច. សេចក្តីសម្រេច ដីកា និងកិច្ចដទៃទៀតរបស់ ស.ច.ស។

ឆ. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ការថតសំឡេង/រូបភាពនៃសវនាការជាសម្ងាត់ [និង]

ជ. ឯកសារដែលដាក់ទៅ អ.ប.ជ រហូតដល់ អ.ប.ជ បានសម្រេចលើបញ្ហានោះ[50]។

20. មាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ប្រភេទ បញ្ជាក់ថា អង្គហេតុដែលថាភ័ស្តុតាងជាក់លាក់ណាមួយ ដែលសហចៅក្រមស៊ើបអង្កេតចាត់ទុកថាជាផ្នែកមួយនៃការស៊ើបអង្កេត មិនចំពោះថាខ្លឹមសារនៃអង្គហេតុនោះជាអ្វីទេ គឺជាព័ត៌មានសម្ងាត់[51]។

21. ក្នុងមាត្រា ៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ប្រភេទ ឯកសារខាងក្រោមជាឯកសារសាធារណៈតាមការសន្មត់៖

ក. អំឡុងពេលនៃការស៊ើបអង្កេតរបស់តុលាការ ឯកសារត្រូវចាត់ជាប្រភេទសាធារណៈ ដោយសហចៅក្រមស៊ើបអង្កេត។

ខ. សារណារបស់អ្នកដែលមិនមែនជាគូភាគីនៃរឿងក្តី (Amicus curiae)។

គ. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ការថតចម្លង/រូបភាពនៃសវនាការសាធារណៈ។

ឃ. ភ័ស្តុតាងដែលរួមមានរបាយការណ៍ជំនាញ ដែលត្រូវបានទទួលយកនៅក្នុងអំឡុងពេលជំនុំជម្រះ ឬនៅពេលដែលប្តឹងឧទ្ធរណ៍។

ង. សាលក្រម និងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះ [និង]

ច. ឯកសារដូចមានចែងក្នុងមាត្រា ៥.១ (ជ) បន្ទាប់ពីអង្គជំនុំជម្រះបានសម្រេចជាឯកសារសាធារណៈ។

[50] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ប្រភេទ មាត្រា ៥.១ (គូសបញ្ជាក់បន្ថែម)។

[51] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ប្រភេទ មាត្រា ៥.២។

22. មាត្រា ៩.១ និង ១២.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ប្រភេទ អនុញ្ញាតឱ្យមានការធ្វើចំណាត់ប្រភេទឯកសារ ឬព័ត៌មានឡើងវិញ អនុលោមតាមដីការបស់ ស.ច.ស ឬ អង្គជំនុំជម្រះ តាមករណីសមស្រប។ មាត្រា ៩.២ និង ៩.៣ ចែងអំពីការកាត់ចេញផ្នែកខ្លះ (កោសលុប) នៃឯកសារ។

## គោលការណ៍ស្តីពីការដាក់ចំណាត់ប្រភេទ និងការដាក់ចំណាត់ប្រភេទឡើងវិញ នៃកិច្ចដំណើរការនីតិវិធីតុលាការ

23. បុព្វកថាភ្ជាប់ទៅនឹងកិច្ចព្រមព្រៀង អ.វ.ត.ក រំលឹកអំពីការព្រួយបារម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ និងការផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ។ បន្ទាប់មកកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> ក្នុងផលប្រយោជន៍ធានាឱ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់។ ការលើកលែងមិនឱ្យចូលរួមស្តាប់ការជំនុំជម្រះក្តីនេះ តាមមាត្រា១៤ នៃ អនុសញ្ញា [ICCPR] អាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណា ដែលការផ្សព្វផ្សាយចេញទៅនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌[52]។

24. កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> ដោយហេតុថា [...] អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តការងារសេសសល់សំខាន់ៗមួយចំនួនដូចមានកំណត់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមនេះ [...] [អ.វ.ត.ក] ត្រូវបន្តបំពេញមុខងារនានាសម្រាប់រយៈពេលបីឆ្នាំដំបូង ដូចតទៅ៖ [...] ផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី [...] ថែទាំ រក្សាទុក និងគ្រប់គ្រងបណ្ណសាររបស់ខ្លួនរួមទាំងការ

[52] កិច្ចព្រមព្រៀង អ.វ.ត.ក, បុព្វកថា មាត្រា ១២(២)។

ធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារសំណុំរឿងទាំងអស់ ឆ្លើយតបទៅនឹងសំណើសុំចូលពិនិត្យមើលឯកសារ ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនពាក់ព័ន្ធនឹង [អ.វ.ត.ក][53]។

អ.ស.ប និង រ.រ.ក យល់ព្រមគ្នាថា ជាការសំខាន់ដែលធានាថា បណ្ណសាររបស់ [អ.វ.ត.ក] ត្រូវបានរក្សាទុកដោយអនុលោមតាមបទដ្ឋានអន្តរជាតិ ហើយសាធារណជន*អាចចូលមើលបានយ៉ាងទូលំទូលាយ*[54]។

ក្នុងគោលបំណងដើម្បីថែរក្សានិងលើកកម្ពស់កេរដំណែលរបស់ [អ.វ.ត.ក] ដែលជាផ្នែកនៃមុខងារសេសសល់របស់ខ្លួន [អ.វ.ត.ក] ត្រូវអនុញ្ញាតឲ្យសាធារណជនមានសិទ្ធិចូលមើលបាននូវសំណៅអេឡិចត្រូនិក និងសំណៅជាក្រដាសនៃបណ្ណសារសាធារណៈ[55]។

25. មាត្រា ៣.១៤ នៃសេចក្ដីណែអនុវត្តស្ដីពីការដាក់ឯកសារ[56] ចែងថា ឯកសារអាចត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ ក្នុងករណីដែលវា “ស្ថិតក្នុងផលប្រយោជន៍យុត្តិធម៌” ក្នុងការធ្វើដូច្នោះ។ សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ចំណាត់ប្រភេទឯកសារទទួលស្គាល់ថា ព័ត៌មានមួយចំនួនតម្រូវឲ្យមានចាត់ចែងយ៉ាងប្រុងប្រយ័ត្នបន្ទាប់ពីកិច្ចដំណើរការនីតិវិធីបានបញ្ចប់។ វាចែងអំពីការការពារជាពិសេសចំពោះសំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ (រួមមាន ការវាយតម្លៃហានិភ័យរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ (“WESU”) ឯកសារនិងព័ត៌មានដែលស្ថិតក្រោមវិធានការការពារ និងព័ត៌មានទាក់ទងនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ[57]។ វាក៏ចែងផងដែរថា CPA ដែលត្រូវបានបដិសេធ ត្រូវបន្តរក្សាការសម្ងាត់ ចំណែកឯព័ត៌មាន

---

[53] កិច្ចព្រមព្រៀងបន្ថែម បុព្វកថា មាត្រា ២(១)។

[54] កិច្ចព្រមព្រៀងបន្ថែម មាត្រា ៣(១) (គូសបញ្ជាក់បន្ថែម)។

[55] កិច្ចព្រមព្រៀងបន្ថែម មាត្រា ៣(២)។

[56] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ វិសោធនកម្មទី៨ (“សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ”) មាត្រា ៣.១៤។

[57] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ចំណាត់ប្រភេទ មាត្រា ៦ (ចែងថា “ជាគោលការណ៍ លើកលែងតែ មានចំណាត់ ថ្នាក់ផ្សេងពីនេះ ដោយសេចក្ដីសម្រេចរបស់តុលាការ ឯកសារ និងព័ត៌មាន ក្នុងចំណាត់ថ្នាក់ [ដូចខាងក្រោមនេះ] ជាឯកសារនិងព័ត៌មានសម្ងាត់”)។

ទំនាក់ទំនងលម្អិតរបស់អ្នកដាក់ពាក្យប្តឹង និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុង VIF ត្រូវធ្វើការកោសលុប ប្រសិនបើឯកសារទាំងនោះត្រូវធ្វើឱ្យទៅជាសាធារណៈ[58]។

26. ភាពចាំបាច់ក្នុងការការពារភាពឯកជនរបស់ជនរងគ្រោះ និងព័ត៌មានផ្ទាល់ខ្លួនដែលរសើប ក៏ត្រូវបាន តម្កល់នៅក្នុងសេចក្តីណែនាំរបស់អគ្គលេខាធិការ អ.ស.ប ផងដែរ សម្រាប់ការធ្វើចំណាត់ប្រភេទ និងការដោះស្រាយចំពោះព័ត៌មានដែលរសើប[59] និងនៅក្នុងសេចក្តីប្រកាសអំពីគោលការណ៍ជា មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច ដែលត្រូវបានអនុម័ត ដោយមហាសន្និបាត។ សេចក្តីប្រកាសនេះចែងថា៖

> ជនរងគ្រោះគួរទទួលបានការប្រព្រឹត្តដោយក្តីករុណា និងសេចក្តីគោរព ចំពោះសេចក្តី ថ្លៃថ្នូររបស់ពួកគេ។ [...] ភាពអើពើនៃដំណើរការតុលាការ និងរដ្ឋបាល ចំពោះតម្រូវការ របស់ជនរងគ្រោះ គួរត្រូវបានសម្របសម្រួលដោយ [...] ការចាត់វិធានការក្នុងការកាត់ បន្ថយភាពរំខានចំពោះជនរងគ្រោះ ការពារភាពឯកជនរបស់ពួកគេ នៅពេលចាំបាច់ និងធានាសុវត្ថិភាពរបស់ពួកគេ ក៏ដូចជាសុវត្ថិភាពរបស់គ្រួសាររបស់ពួកគេ និងសាក្សី នានាក្នុងនាមពួកគេ មិនឱ្យមានការគំរាមកំហែង និងការសងសឹក [។][60]

[58] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ប្រភេទ មាត្រា ៧.២, ៧.៤។ *សូមមើលផងដែរ* កថាខណ្ឌ ៣ *យោងខាងលើ* និងការយោងសំអាងខាងក្នុងនោះ។

[59] *សូមមើល ឧទាហរណ៍* ព្រឹត្តិប័ត្ររបស់អគ្គលេខា "ព័ត៌មានដែលមិនចង់ឱ្យគេដឹងឮអំពី ការធ្វើចំណាត់ប្រភេទ និង ការដោះស្រាយ" ST/SGB/2007/6, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ ផ្នែក ១.២ ("ព័ត៌មានដែល គេជឿជាក់ថា មិនចង់ឱ្យគេដឹងឮអំពី រួមមានដូចខាងក្រោម [...] (ខ) ឯកសារទាំងឡាយណាដែលការដាក់បង្ហាញរបស់ពួកវា អាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាព ឬសន្តិសុខរបស់បុគ្គលណាម្នាក់ រំលោភលើសិទ្ធិរបស់គាត់ ឬបំពានលើភាពឯកជនរបស់គាត់។ [...] (ឆ) ព័ត៌មានប្រភេទផ្សេងទៀត ដោយហេតុថាខ្លឹមសាររបស់ពួកវា ឬកាលៈទេសៈនានានៃការបង្កើតឯកសារនោះ ឬការប្រាស្រ័យទំនាក់ទំនងត្រូវតែរក្សាជាសម្ងាត់។")។ ព្រឹត្តិប័ត្ររបស់អគ្គលេខា "សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ៖ ព័ត៌មានដែលមិនចង់ឱ្យគេដឹងឮអំពី ការធ្វើចំណាត់ប្រភេទ ការដោះស្រាយ និងការចូលមើល" ST/SGB/2012/3, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ផ្នែក ៤.២ ("បន្ថែមលើឯកសារ និង ព័ត៌មានដែលបានកំណត់អត្តសញ្ញាណថាមិនចង់ឱ្យគេដឹងឮ នៅក្នុង ST/SGB/2007/6 ឯកសារ និងព័ត៌មានដែលមិនចង់ឱ្យគេដឹងឮត្រូវរួមបញ្ចូលដូចខាងក្រោម៖ [...] (ខ) [...] ឯកសារដែលមានព័ត៌មានដែល ប្រសិនបើដាក់បង្ហាញមិនមានការអនុញ្ញាតត្រឹមត្រូវ អាចបង្ហាញអត្តសញ្ញាណរបស់សាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀតដែលត្រូវការពារ។")។

[60] សេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច ត្រូវបាន អនុម័តដោយ UN G.A. Res. 40/34, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ កថាខណ្ឌ ៤, ៦។

27. សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានឈានទៅដល់មុខងារសេសសល់ បានបង្កើតគោលការណ៍ចូលមើលផ្លូវការ ដើម្បីធានាថា ផលប្រយោជន៍នានាត្រូវបានថ្លឹងថ្លែងត្រឹមត្រូវ និងត្រូវបានគោរពយ៉ាងស៊ីចង្វាក់។ នៅតុលាការពិសេសនៃមុខងារសេសសល់សម្រាប់សៀរ៉ាឡេអូន ("RSCSL") គោលការណ៍ចូលមើលនេះចែងថា៖

> ការងាររបស់ RSCSL ត្រូវតែមានលក្ខណៈបើកចំហ និងតម្លាភាព លើកលែងតែក្នុងកម្រិតដែលថា សភាពនៃឯកសារ និងព័ត៌មានដែលពាក់ព័ន្ធ មានលក្ខណៈរសើប [...]។ សម្រាប់គោលបំណងនៃគោលការណ៍នេះ និងស្របទៅនឹងគោលការណ៍ស្តីពីឯកសារ និងបណ្ណសាររបស់ RSCSL ឯកសារនិងព័ត៌មានដែលរសើប គួររួមបញ្ចូល [...] ឯកសារ និងព័ត៌មានទាក់ទងនឹងការការពារសាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀត ដែលបានយោងនៅក្នុងភស្តុតាង ឬម្យ៉ាងវិញទៀត ទាក់ទងទៅនឹងដំណើរការតុលាការ រួមមាន ឯកសារ ដែលមានព័ត៌មាន ដែល ប្រសិនបើដាក់បង្ហាញដោយមិនមានការអនុញ្ញាតត្រឹមត្រូវ អាចបង្ហាញអត្តសញ្ញាណ និងទីកន្លែងរបស់សាក្សី ជនរងគ្រោះ និងបុគ្គល ដែលងាយរងគ្រោះផ្សេងទៀតដែលត្រូវការពារ[61][។]

គោលការណ៍ចូលមើលសម្រាប់ឯកសារដែលតម្កល់ដោយ IRMCT ចែងថា ព័ត៌មានដែល*រួចផុត*ពីការដាក់បង្ហាញទៅសាធារណជនរួមមាន៖

> ឯកសារនិងព័ត៌មានដែលការដាក់បង្ហាញរបស់ពួកវាអាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាព ឬសន្តិសុខរបស់បុគ្គលណាម្នាក់ រំលោភលើសិទ្ធិរបស់គាត់ ឬបំពានលើភាពឯកជនរបស់គាត់។ ចំណុចនេះត្រូវរួមបញ្ចូលទាំងឯកសារ និងព័ត៌មានដែលទាក់ទងនឹងការការពារសាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀត ដែលត្រូវបានយោងនៅក្នុងភស្តុតាង ដែលបានបង្ហាញនៅចំពោះមុខតុលាការ ICTR, ICTY ឬ យន្តការ ឬម្យ៉ាងវិញទៀត ទាក់ទងនឹងដំណើរការតុលាការ រួមមាន ឯកសារដែលមានព័ត៌មានដែលប្រសិនបើដាក់បង្ហាញ ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ នឹងបង្ហាញអត្តសញ្ញាណ និងទីកន្លែងរបស់សាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀតដែលត្រូវ

[61] តុលាការពិសេសនៃមុខងារសេសសល់សម្រាប់សៀរ៉ាឡេអូន៖ ឯកសារ និងព័ត៌មានដែលមិនចង់ឲ្យគេដឹងឮអំពី ការធ្វើចំណាត់ប្រភេទ ការផ្លាស់ប្តូរក្នុងការធ្វើចំណាត់ប្រភេទនិងគោលការណ៍ចូលមើល RSCSL ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ ផ្នែក ៤.១, ៤.២(ខ)។

ការពារ។ ចំណុចនេះក៏ត្រូវបញ្ចូលផងដែរនូវព័ត៌មានផ្ទាល់ខ្លួន ដែលពាក់ព័ន្ធទៅនឹងបុគ្គល គ្រួសារ របស់បុគ្គល ដែលត្រូវបាន ឬកំពុងឃុំខ្លួនដោយតុលាការ ICTR, ICTY ឬ យន្តការ[62]។

## សម្ភារដែលត្រូវបានរក្សាសិទ្ធិអ្នកនិពន្ធ

28. សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ចំណាត់ប្រភេទ ចែងថា "ឯកសារដែលបានធ្វើចំណាត់ថ្នាក់រួច ហើយជាសាធារណៈ សាធារណជនអាចចូលអានបាន។ ប៉ុន្តែឯកសារណាដែលមានការរក្សាសិទ្ធិអ្នកពិនព្ធ ឬត្រូវមានការយល់ព្រមពីតតិយជនដែលបានហាមឃាត់ មិនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឡើយ លើកលែងតែមានការអនុញ្ញាតពីតតិយជននេះ"[63]។

## IV. សារណា

## ក. ការសម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ

29. អាណត្តិសំខាន់ជាងគេនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក - ដែលមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀង វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងយុត្តិសាស្ត្ររបស់ខ្លួន - ជាពិសេស វិធាន ២១ គឺតម្លាភាពជាអតិបរមា ដែលស្របទៅនឹងការបំពេញមុខងារសមស្របរបស់តុលាការ។ ហេតុដូច្នេះ ដោយមានការលើកលែងតិចតួចបំផុត សេចក្ដីសម្រេចរបស់ អ.ប.ជ ទាំងអស់គឺសាធារណៈ[64] រាល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះទាំងអស់ធ្វើឡើងជាសាធារណៈ[65] សាលក្រមជំនុំជម្រះត្រូវចេញជាសាធារណៈ[66] កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខធ្វើឡើងជាសាធារណៈ[67]

---

[62] គោលការណ៍ចូលមើលសម្រាប់ឯកសារតម្កល់ដោយយន្តការសម្រាប់សាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិ IRMCT, MICT/17/វី១ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ("គោលការណ៍ចូលមើលសម្រាប់ IRMCT") មាត្រា ១០(៣)(ខ)។ *សូមមើលផងដែរ* មាត្រា ៧(២)។

[63] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ចំណាត់ប្រភេទ មាត្រា ១២.៣។

[64] វិធាន ៧៨។

[65] វិធាន ២៩(៤)(ង), ៧៩(៦)។

[66] វិធាន ៧៩(៦)(ខ)។

[67] វិធាន ១០៩(១)។

សាលដីកាបណ្តឹងសាទុក្ខត្រូវចេញជាសាធារណៈ[68] ហើយនៅពេលបិទបញ្ចប់រឿងក្តី ឯកសារសម្ងាត់ដែលនៅសេសសល់ត្រូវពិនិត្យឡើងវិញ ដើម្បីធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈ[69]។

30. វិធាន ៥៦(១) ផ្តល់ការលើកលែងដ៏មានកម្រិត និងសមហេតុផលចំពោះគោលការណ៍សំខាន់ជាងគេនេះ តាមរយៈការកំណត់អាណត្តិថា ក្នុងអំឡុងរយៈពេលដែលការស៊ើបអង្កេតកំពុងត្រូវបានធ្វើឡើង សច្ចធារណ៍គឺជាការសម្ងាត់។ ការសម្ងាត់ជួយធានាថា សាក្សីមិនទទួលឥទ្ធិពលពីសក្ខីកម្មរបស់អ្នកផ្សេង និងជួយការពារផលប្រយោជន៍របស់ភាគី និងសុចរិតភាពនៃការស៊ើបអង្កេតដែលកំពុងធ្វើរួមទាំងការធានាដល់សន្តិសុខរបស់សាក្សី[70]។ សច្ចធារណ៍នៃការសម្ងាត់នៃកិច្ចស៊ើបសួរគឺជាគោលការណ៍គ្រឹះរបស់ អ.វ.ត.ក[71] នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា[72] និងបារាំង[73]។ សហព្រះរាជអាជ្ញាសូមធ្វើការសង្កេតសំខាន់ពីរ។

31. ទីមួយ ពាក្យពេចន៍ធម្មតានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងច្បាស់ថា សច្ចធារណ៍នេះមានតែសម្រាប់រយៈពេលនៃការស៊ើបអង្កេតដែល*កំពុងធ្វើ*ប៉ុណ្ណោះ។ វិធាន ៥៦(១) គ្រាន់តែតម្រូវថា ការស៊ើបអង្កេតមិនត្រូវ "ធ្វើ" ជាសាធារណៈឡើយ និងថា អ្នកដែល "ចូលរួម" ក្នុងការស៊ើបអង្កេត

---

[68] វិធាន ១០២។

[69] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ មាត្រា ១២.១, ១២.២។

[70] *សូមមើលឧទាហរណ៍* សំណុំរឿង ០០១-**F30/2** សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៦។ សំណុំរឿង ០០៤/១-**D309/2/1/7** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីការកោសលុបក្នុងដីកាដំណោះស្រាយ") កថាខណ្ឌ ៣៦ ("[អ.ប.ជ] សូមរំលឹកឡើងវិញថា ការស៊ើបអង្កេតនៅតែរក្សាការសម្ងាត់រហូតដល់ពេលមានការស៊ើបមូល ដើម្បីការពារសុចរិតភាព និងផលប្រយោជន៍របស់ភាគី")។ សំណុំរឿង ០០៤-**D193/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញបទសម្ភាសន៍សំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៤ កថាខណ្ឌ ៩។

[71] វិធាន ៥៦(១)។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសកម្ពុជា មាត្រា ១២១។

[73] ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង មាត្រា ១១ ("Sauf dans le cas où la loi en dispose autrement et sans préjudice des droits de la défense, la procédure au cours de l'enquête et de l'instruction est secrète." បកប្រែក្រៅផ្លូវការ៖ "លើកលែងតែកន្លែងណាដែលច្បាប់ចែងខុសពីនេះ និងដោយគ្មានការរើសអើងចំពោះសិទ្ធិការពារក្តី នីតិវិធីក្នុងអំឡុងពេលស៊ើបអង្កេតបឋម និងការស៊ើបអង្កេតតាមផ្លូវតុលាការ គឺរក្សាការសម្ងាត់។")។

ត្រូវរក្សាការសម្ងាត់។ ការបកស្រាយនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ អ.វ.ត.ក ទាំងអស់។ បន្ទាប់ពីសំណុំរឿង ០០១ បានបិទបញ្ចប់ អ.ជ.ត.ក បានទទួលស្គាល់ថា មូលហេតុនានាសម្រាប់ការធ្វើចំណាត់ប្រភេទឯកសារពីដំបូង ដែលបានផ្តល់ឲ្យឯកសារទាំងនោះ មិនមានទៀតទេ[74] ហើយបានចេញសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដោយចែងថា៖

> ឯកសារដែលមានតម្លៃជាច្រើននៅក្នុងសំណុំរឿង ត្រូវបានប្រមូលនៅក្នុងអំឡុងពេលដំណើរការកិច្ចស៊ើបសួរ។ ដោយហេតុថាកិច្ចដំណើរការនីតិវិធី [...] បានបញ្ចប់រួចហើយ *ការដកចំណាត់ថ្នាក់ឯកសារដែលពាក់ព័ន្ធកិច្ចស៊ើបសួរ លែងមានហានិភ័យជាទូទៅនៃការប៉ះពាល់លើសិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរ*[75]។

អ.ជ.ស.ដ[76], និង អ.ប.ជ[77] បានធ្វើសេចក្តីថ្លែងស្រដៀងគ្នា នៅពេលដែលការស៊ើបអង្កេតបានបិទបញ្ចប់ ការសម្ងាត់ដែលតម្រូវដោយពាក្យពេចន៍ជាក់លាក់នៃវិធាន ៥៦(១) អាចត្រូវបានដកចេញ[78]។

---

[74] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាខណ្ឌ ២ ("អង្គជំនុំជម្រះតុលាការកំពូលបានសុំអញ្ជើញភាគី និងការិយាល័យនានាដែលពាក់ព័ន្ធ សាជាថ្មីទៀត [...] ឲ្យផ្តល់ការណែនាំដល់អង្គជំនុំជម្រះ ប្រសិនបើនៅមានហេតុផលផ្សេងៗក្នុងការមិនផ្សព្វផ្សាយឯកសារមួយចំនួន ឬមិនផ្សព្វផ្សាយប្រភេទនៃឯកសារផ្សេងៗ នៅក្នុងដំណាក់កាលកិច្ចដំណើរការនីតិវិធីនៅពេលនេះ")។

[75] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៦។

[76] *សូមមើលឧទាហរណ៍* ឯកសារ **E313** សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣៩។ ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥។

[77] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៣-**D147/1** សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំឲ្យធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈនូវសារណាជាក់លាក់របស់មេធាវីការពារក្តីដាក់ទៅកាន់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ("សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញនៃសារណារបស់មេធាវីការពារក្តី") កថាខណ្ឌ ៦ ("យោងតាម [វិធាន ៥៦] ដែលថាកិច្ចដំណើរការនីតិវិធី *ក្នុងអំឡុង*ពេលកិច្ចស៊ើបសួរ *គឺថា រហូតដល់ពេលចេញដីកាដំណោះស្រាយជាផ្លូវការ* គឺជាគោលការណ៍ជាការសម្ងាត (គូសបញ្ជាក់បន្ថែម)")។ សំណុំរឿង ០០៤/១-**D309/2/1/7** សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីការកោសលុបក្នុងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦។ ឯកសារ **C20/I/27** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទអៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៦ ("ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំរឿង ត្រូវរក្សាការសម្ងាត់*នៅក្នុងដំណាក់កាលនេះ ដោយសារអង្គហេតុទាំងឡាយនៅកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនៅឡើយ* (គូសបញ្ជាក់បន្ថែម")។

32. ទីពីរ ការសម្ងាត់នៃកិច្ចស៊ើបសួរមិនដាច់ខាតទេ។ ក្របខ័ណ្ឌគតិយុត្តិ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ពោរពេញទៅដោយការយោងនានាទៅលើភាពចាំបាច់ ក្នុងការរក្សាតុល្យភាពរវាងការសម្ងាត់នៃកិច្ចស៊ើបសួរ ជាមួយនឹងផលប្រយោជន៍ផ្សេងទៀត រួមទាំងផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ និងជនរងគ្រោះ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី ដែលមានចែងក្នុងវិធាន ២១(១) ផលប្រយោជន៍យុត្តិធម៌ និង សណ្តាប់ធ្នាប់សាធារណៈ និងគោលបំណងអប់រំ កេរដំណែល និងការផ្សះផ្សា ក៏ដូចជាភាពប្រាកដប្រជាផ្នែកច្បាប់។ ការធ្វើការថ្លឹងថ្លែងនេះអនុវត្តសូម្បីតែ*ក្នុងអំឡុងពេល*កិច្ចស៊ើបសួរ[79] ទោះបីជាមានការផ្តល់ទម្ងន់ច្រើនជាងទៅលើការរក្សាការសម្ងាត់របស់វាក្តី។ ទោះជាយ៉ាងណា ក្រោយការស៊ើបអង្កេតចប់[80] និងជាពិសេសនៅពេលនេះ ដែល អ.វ.ត.ក កំពុងឆាកទៅរកដំណាក់កាលសេសសល់របស់ខ្លួននោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ផលប្រយោជន៍អប់រំ កេរដំណែល និងការផ្សះផ្សា មានភាពចាំបាច់។ ជាក់ស្តែង នៅពេលចៅក្រមរបាយការណ៍បង្ហាញអនុសាសន៍របស់ខ្លួនស្តីពីការផ្តួចផ្តើមសម្រាប់មុខងារសេសសល់របស់ អ.វ.ត.ក ចៅក្រម Claudia Fenz បានលើកឡើងថា "ដំណាក់កាលនៅសេសសល់ [របស់

---

[78] *សូមមើលផងដែរ* C. Guéry និង P. Chambon, *Droit et pratique de l'instruction préparatoire*, បោះពុម្ពលើកទី១០ (២០១៧), Dalloz Action, s. 31.44 ("C'est pendant le cours de l'enquête et de l'instruction, tant qu'elles ne sont pas terminées, que s'applique avec toute son intensité le secret édicté par l'article 11 du Code de procédure pénale. […] Après la clôture de l'information et le renvoi de l'affaire devant la juridiction de jugement, la règle de la publicité remplace celle du secret." បកប្រែក្រៅផ្លូវការ៖ វាគឺជាអំឡុងពេលនៃការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតតាមផ្លូវតុលាការ ដរាបណាពួកវាមិនត្រូវបានបញ្ចប់ នោះការរក្សាការសម្ងាត់ដែលបានអនុម័តដោយមាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវអនុវត្តជាមួយនឹងភាពតឹងរឹងរបស់វា។ បន្ទាប់ពីការបិទការស៊ើបអង្កេតតាមផ្លូវតុលាការ និងការបញ្ជូនសំណុំរឿងទៅតុលាការជំនុំជម្រះ វិធាននៃការផ្សព្វផ្សាយជាសាធារណៈជំនួសការរក្សាការសម្ងាត់នោះ")។

[79] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ១.២, ៤(ក), ៤(ច), វិធាន ៥៦(២)។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៣.១២។ អ.ប.ជ Doc No. 4 សេចក្តីណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៣, ៧, ១០។ Case 003-**D147/1** សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញនៃសារណារបស់មេធាវីការពារក្តី ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ៦-៨។ សំណុំរឿង ០០៣-**D56/19/20** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី មាស មុត សុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈនូវសារណាទំនាស់ផលប្រយោជន៍ទាំងអស់ និងសារណាផ្សេងទៀតរបស់មេធាវីការពារក្តី នៅចំពោះមុខអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ កថាខណឌ ៦-៩។

[80] ការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ និងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទាំងអស់ត្រូវបានបញ្ចប់ត្រឹមឆ្នាំ២០១១។ *សូមមើលយោងខាងលើ* កថាខណ្ឌ ៧។

អ.វ.ត.ក] ទទួលស្គាល់ដោយខ្លួនឯងថាជាការចូលរួមចំណែកដល់ដំណើរការព្យាបាលរបួសស្នាមរបស់ជនរងគ្រោះ និងការជំរុញជាទ្រង់ទ្រាយធំដល់ការផ្សះផ្សាជាតិ”[81]។

33. នៅពេលធ្វើការពិនិត្យលើការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះនេះបានសម្រេចថា ជាគោលការណ៍ ឯកសារទាំងអស់ពីរយៈកាលស៊ើបអង្កេតគួរធ្វើឱ្យទៅជាសាធារណៈ “ដូច្នេះត្រូវអនុញ្ញាតឱ្យសាធារណជនទូទៅមានលទ្ធភាពពេញលេញក្នុងការពិនិត្យមើលឯកសារ និងពង្រីកឱ្យមានតម្លាភាពដល់កម្រិតអតិបរមា”[82]។ អង្គជំនុំជម្រះបានសង្កេតថា៖

> ការធ្វើចំណាត់ថ្នាក់លើឯកសារត្រូវធ្វើឡើង ដោយធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងតម្រូវការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាពដែលកើតចេញពីគោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការក្នុងការអប់រំ និងរក្សាកេរដំណែល។ ដូច្នេះ អង្គជំនុំជម្រះនេះសូមរំលឹកឡើងវិញថា ‘ការចែកចាយឱ្យបានទូលំទូលាយនូវសម្ភារពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ [...] គឺស្របទៅនឹងអាណត្តិរបស់ អ.វ.ត.ក ដែលរួមមានទាំងការចូលរួមចំណែកនៅក្នុង*ការផ្សះផ្សាជាតិ* និងការផ្ដល់ឱ្យនូវឯកសារ ដើម្បីគាំទ្រដល់ការស្វែងរកការពិតខាងផ្នែកប្រវត្តិសាស្ត្រដ៏យូរអង្វែងមកហើយ’។ ការចែកចាយភស្តុតាងសំខាន់ៗជាច្រើនដែលមាននៅក្នុងសំណុំរឿង ០០១ អាចជម្រុញឱ្យមាន *‘កិច្ចពិភាក្សាលើអតីតកាលជាសាធារណៈ និងដោយមិនមានការលាក់លៀម ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំមួយដែលជាលទ្ធផល អាចកាត់បន្ថយនូវទស្សនៈនៃការមិនទទួលស្គាល់ ការបំភ្លៃអង្គហេតុ និងការពិតដែលមានតែមួយផ្នែកនោះបាន’*[83]។

---

[81] សេចក្ដីប្រកាសព័ត៌មាន អ.វ.ត.ក *សហចៅក្រមរបាយការណ៍ដាក់ជូនរបាយការណ៍របស់ខ្លួន ស្ដីពីមុខងារនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ* ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១។

[82] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្ដីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៦។

[83] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្ដីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាណ្ឌ ៥ គូសបញ្ជាក់បន្ថែម *ដកស្រង់* សំណុំរឿង ០០១-**F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ (“សាលដីកា *ឌុច*”) កថាខណ្ឌ ៧០៨។ ការផ្ដល់នូវមូលដ្ឋានការពិតដ៏ត្រឹមត្រូវអាចជួយបដិសេធការមិនពិត និងការបដិសេធនិយម ជាពិសេសនៅក្នុងសង្គមដែលបែកបាក់បន្ទាប់ពីមានជម្លោះ។ *សូមមើលឧទាហរណ៍* Diane Orentlicher, *Memories of Judgment: Constructing the ICTY's Legacies*, 19(3) Wash. U. Global Stud. L. Rev. (២០២០), ទំព័រ ៣១៦, ៣១៨-៣១៩, ៣២៤ (បានកត់សម្គាល់ផងដែរថា អ្នករស់រានមានជីវិតពីការសម្លាប់រង្គាល (Holocaust) និងជ័យលាភីរង្វាន់ណូបែល Elie Wiesel ជឿថាមាន

34. ការណ៍នេះស្របទៅនឹងយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច ដែលបានបញ្ជាក់ផងដែរអំពីការចង់ឱ្យមានតម្លាភាពខ្លាំងនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ ("STL") បានសង្កេត "អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") បានសម្រេចយ៉ាងស៊ីចង្វាក់ថា សេចក្តីសម្រេចទាំងអស់ និងសារណាទាំងអស់ដែលបានដាក់នៅចំពោះមុខសាលាក្តី ត្រូវតែសាធារណៈ លុះត្រាតែមានមូលហេតុ*ពិសេស*សម្រាប់រក្សាទុកពួកវាជាសម្ងាត់"[84]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកត់សម្គាល់ថា សិទ្ធិចូលមើលជាសាធារណៈ "ផ្តល់ការការពារប្រឆាំងនឹងការសម្រេចចិត្តតាមអំពើចិត្ត និងបង្កើតទំនុកចិត្តដោយអនុញ្ញាតឱ្យសាធារណជនមើលឃើញយុត្តិធម៌"[85]។ អង្គជំនុំជម្រះសាលាដំបូងទីពីរនៃតុលាការ ICTY បានកត់សម្គាល់ថា ចង់បានឱ្យមានការចូលមើលជាសាធារណៈចំពោះកិច្ចការរដ្ឋបាលរបស់តុលាការ ពីព្រោះ "សាលាក្តីអន្តរជាតិមានមុខងារអប់រំ ហើយការបោះពុម្ពផ្សាយសកម្មភាពរបស់ខ្លួន ជួយឱ្យសម្រេចបានគោលដៅនេះ"[86]។

35. អតីតប្រធានតុលាការ ICTY ចៅក្រម Theodor Meron បានសរសេរថា៖

> តម្លាភាពមានសារសំខាន់ក្នុងការកសាងទំនុកចិត្តសាធារណៈ ក្នុងការគ្រប់គ្រងដោយត្រឹមត្រូវយុត្តិធម៌ - ហើយទំនុកចិត្តសាធារណៈគឺចាំបាច់ក្នុងការជំរុញការយល់ដឹងទូលំទូលាយ និងគាំទ្រដល់ការងាររបស់សាលាក្តី។ តម្លាភាពក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការក៏ដើរតួជាការការពារដ៏សំខាន់ប្រឆាំងនឹងការធ្វើតាមអំពើចិត្តរបស់តុលាការ

---

កាតព្វកិច្ចក្នុងការថែរក្សាការចងចាំពីភាពភ័យរន្ធត់របស់ Third Reich ព្រោះវាជាមធ្យោបាយប្រាកដបំផុតដើម្បីគាំទ្រនូវអ្វីដែលពួកណាហ្ស៊ី បានស្វែងរកដើម្បីសម្រេចបាន ដែលជាការលុបបំបាត់ការចងចាំ ហើយជាមួយនឹងការចងចាំនោះ គឺវប្បធម៌ខ្លួនវាផ្ទាល់)។

[84] *Ayyash និងគូកន.*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្តីសម្រេចលើសំណើរបស់ចៅក្រមអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៦៨(ឆ) ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ("សេចកក្តីសម្រេចក្នុងរឿងក្តី *Ayyash*") កថាខណ្ឌ ១៣ ជើងទំព័រ ៣៤ (គូសបញ្ជាក់បន្ថែម)។

[85] *Delalić និងគូកន.*, អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើញត្តរបស់អយ្យការសុំវិធានការការពារសម្រាប់សាក្សីអយ្យការដែលមានរហស្សនាម "B" ដល់ "M" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៧ កថាខណ្ឌ ៣៤។

[86] *Tadić*, អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញា ស្នើសុំវិធានការការពារជនរងគ្រោះ និងសាក្សី ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៥ កថាខណ្ឌ ៣២។

និងជួយធានា មិនត្រឹមតែភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឯករាជ្យភាព និងភាពមិនលំអៀងរបស់ចៅក្រម និងការព្យាករណ៍អំពីការសម្រេចចិត្តរបស់តុលាការផងដែរ។ ហើយតម្លាភាព ប្រហែលជាមានសារសំខាន់ជាពិសេសនៅក្នុងតុលាការព្រហ្មទណ្ឌ ដូចជាសាលាក្តី ដែលបញ្ហាដែលពាក់ព័ន្ធ - រួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដ៏គួរឱ្យរន្ធត់ និងការសម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ - ធ្វើឱ្យវាកាន់តែចាំបាច់ក្នុងការមានការប្រកាន់ខ្ជាប់យ៉ាងច្បាស់លាស់ និងជាក់ស្តែង ទៅនឹងបទដ្ឋាននៃដំណើរការត្រឹមត្រូវដែលទទួលស្គាល់ជាអន្តរជាតិ[87]។

36. លក្ខន្តិកៈ និងវិធាននៃសាលាក្តីអន្តរជាតិ និងអន្តរជាតូបនីយកម្មផ្សេងទៀតបង្ហាញថា គោលការណ៍ស្តីពីតម្លាភាពអនុវត្តទៅលើឯកសារដែលបង្កើតឡើងនៅដំណាក់កាលមុនការជំនុំជម្រះ។ តុលាការ STL ដែលដូចគ្នានឹង អ.វ.ត.ក គឺជាសាលាក្តីកូនកាត់ផ្អែកលើគំរូច្បាប់ស៊ីវិលឡ៍ តម្រូវថា ដោយមានការលើកលែងតិចតួច "ការដាក់ឯកសារមុនការជំនុំជម្រះ កិច្ចដំណើរការនីតិវិធី និងដីកាត្រូវជាសាធារណៈ"[88]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ STL ដែលដោះស្រាយបញ្ហាមុនការជំនុំជម្រះ បានលើកឡើងថា អង្គជំនុំជម្រះ "មានការប្រុងប្រយ័ត្នក្នុងការសង្កត់ធ្ងន់លើតម្រូវការឱ្យមានតម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខសាលាក្តីនេះ" និងបានកត់សម្គាល់ថា៖ "សារណា និងសេចក្តីសម្រេចសម្ងាត់ - ទោះបីជាពេលខ្លះចាំបាច់ - តាមធម្មជាតិរបស់វាប្រឆាំងគ្នាទៅនឹងគោលនយោបាយនៃការបើកចំហនេះ។ ពួកវាគួរតែរក្សាទុកតិចតួចបំផុត និងអាចធ្វើយុត្តិកម្មបានតែសម្រាប់មូលហេតុពិសេសប៉ុណ្ណោះ ដែលអាចរួមបញ្ចូលការការពារជនរងគ្រោះ និងសាក្សី និងការការពារការស៊ើបអង្កេតដែល*កំពុងធ្វើ*"[89]។

37. តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") តម្រូវថា ដោយមានការលើកលែងតិចតួច "ប្រព័ន្ធគ្រប់គ្រងទិន្នន័យមួយដែលមានចំណុចជាក់លាក់ទាំងអស់នៃរឿងក្តីនីមួយៗ ដែលមាននៅចំពោះមុខតុលាការនេះ" ត្រូវអាចចូលមើលបានជាសាធារណៈ[90]។ សេចក្តីអត្ថាធិប្បាយភ្ជាប់ទៅនឹងលក្ខន្តិកៈទីក្រុងរ៉ូម

[87] Theodor Meron, *The Making of International Criminal Justice: A View from the Bench,* ឆ្នាំ២០១១ ទំព័រ ២៧៨។

[88] សាលាក្តីពិសេសសម្រាប់ប្រទេសលីបង់ វិធាននីតិវិធី និងភស្តុតាង វិធាន ៩៦។

[89] សេចក្តីសម្រេចក្នុងរឿងក្តី *Ayyash* កថាខណ្ឌ ១២ (គូសបញ្ជាក់បន្ថែម)។

[90] តុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាននីតិវិធី និងភស្តុតាង វិធាន ១៥(១)។

បានកត់សម្គាល់ពីសារសំខាន់នៃសិទ្ធិចូលមើលជាសាធារណៈចំពោះ "ការបំពេញមុខងាររបស់ស្ថាប័នសាធារណៈ និងអន្តរជាតិ"[91]។ នៅតុលាការ ICC "ឯកសារដែលមានបទចោទប្រកាន់" ដែលផ្អែកលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ ស្តីពីការបញ្ជាក់លើបទចោទអនុលោមតាមមាត្រា ៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម គឺជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធីដូចគ្នាទៅនឹងដីកាដំណោះស្រាយនៅ អ.វ.ត.ក ដែរ[92]។ ការអនុវត្តរបស់តុលាការ ICC គឺត្រូវស្តាប់សវនាការសាក្សីនៅដំណាក់កាលបញ្ជាក់ជាសាធារណៈ (លើកលែងតែបញ្ហាសន្តិសុខតម្រូវឱ្យមានវិធានការការពារសាក្សី) និងត្រូវចេញសេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទជាសាធារណៈ ដោយមានការកោសលុបកំណត់ត្រឹមតែឈ្មោះរបស់សាក្សី និងជនរងគ្រោះ ដែលត្រូវការពារ។ ចំណុចនេះអនុវត្តដូចគ្នាក្នុងករណីដែលការចោទប្រកាន់មិនត្រូវបានតម្កល់[93]។ ក្នុងការលើកឡើងអំពីបញ្ហាថាតើ ត្រូវធ្វើចំណាត់ប្រភេទទៅជាសាធារណៈ ឬយ៉ាងណា ចំពោះឯកសារដែលត្រូវបានបង្កើតឡើងដោយមានបោះត្រានៅដំណាក់កាលមុនការជំនុំជម្រះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានសម្រេចជាឯកច្ឆ័ន្ទឱ្យធ្វើឱ្យទៅជាសាធារណៈ ក្នុងករណីដែលមូលហេតុសម្រាប់ការសម្ងាត់នោះលែងមានទៀតហើយ[94]។

38. បណ្ណសាររបស់ អ.វ.ត.ក មានកំណត់ត្រាពេញលេញបំផុតរបស់ពិភពលោកនៃឯកសារទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ("DK") និងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលសម័យកាលនោះ។ មានការចាប់អារម្មណ៍ខ្លាំងក្នុងការធានាថា សាធារណជនអាចចូលមើលបណ្ណសាររបស់ អ.វ.ត.ក បានយ៉ាងស្រួល ដើម្បីសម្រួលដល់ការអប់រំ និងការស្រាវជ្រាវក្នុងព្រឹត្តិការណ៍សម័យកម្ពុជាប្រជាធិបតេយ្យ។ ជាក់ស្តែង អង្គជំនុំជម្រះនេះបានសង្កត់ធ្ងន់ថា "ការយល់ដឹងរបស់សាធារណជន និងការពិភាក្សាវែកញែកអំពីទំព័រប្រវត្តិសាស្ត្រកម្ពុជាដ៏សោកនាដកម្ម

---

[91] Antonio Cassese និងអ្នកផ្សេងទៀត, ed., *The Rome Statute of the International Criminal Court: a Commentary*, រោងពុម្ព Oxford University Press, ឆ្នាំ២០០២ ទំព័រ ១២៨១។

[92] លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦១។

[93] *សូមមើលឧទាហរណ៍* *Abu Garda*, អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើការបញ្ជាក់បទចោទ សំណៅកោសលុបសាធារណៈ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០។ *Mbarushimana*, អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើការបញ្ជាក់បទចោទ សំណៅកោសលុបសាធារណៈ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១។

[94] *Kony និងគូកន.*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ស្តីពីការបើកឯកសារ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ៥។

ទាំងនេះ គឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរកជ័យជំនះឲ្យប្រជាជនកម្ពុជា"[95]។ ចៅក្រមរបាយការណ៍ក៏បានសង្កត់ធ្ងន់ថា ភាពចាំបាច់សម្រាប់ការស្វែងយល់អំពីផ្នែកមួយនៃប្រវត្តិសាស្ត្រកម្ពុជានេះ មិនកម្រិតត្រឹមតែជនរងគ្រោះផ្ទាល់នោះទេ អ្នកទាំងឡាយដែលបានកើតនៅក្នុងពេលរបបខ្មែរក្រហម បានទទួលរងផលប៉ះពាល់តាមរយៈការរស់នៅក្នុងរបួសផ្លូវចិត្តដែលឪពុកម្ដាយ សាច់ញាតិ និងបងប្អូនប្រជាពលរដ្ឋរបស់ពួកគេបានទទួលរង និងផលវិបាកផ្នែកសង្គមធំជាងនេះទៀត ដែលកើតមានក្រោយមកទៀត[96]។ ជាការពិត ការសិក្សាអំពីផលប៉ះពាល់បានបង្ហាញថា ភាពចាំបាច់ក្នុងការបញ្ជាក់ការពិត និងការអប់រំអំពីព្រឹត្តិការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺស្ថិតក្នុងចំណោមកេរដំណែលសំខាន់បំផុតរបស់អង្គជំនុំជម្រះ តាមការមើលឃើញរបស់ប្រជាជនកម្ពុជា[97]។ ការបង្កើនលទ្ធភាពចូលមើលឯកសារ និងសម្ភារសោទស្សន៍ត្រូវបានចង្អុលបង្ហាញដោយអ្នកអប់រំ និងអ្នកជំនាញ ថាជាកេរដំណែលគន្លឹះរបស់ អ.វ.ត.ក ដែលអនុញ្ញាតឲ្យមានការបង្រៀនផ្អែកលើភ័ស្តុតាង[98]។

39. ការធ្វើឲ្យឯកសារ អ.វ.ត.ក អាចចូលមើលបានជាសាធារណៈដូចដែលអាចធ្វើទៅបាន នឹងជួយផងដែរដល់ការបង្ហាញបន្ថែមទៀតអំពីភាពអាចជឿជាក់បាននៃកិច្ចដំណើរការនីតិវិធី[99] ដើម្បីលើកកម្ពស់កេរដំណែលរបស់ អ.វ.ត.ក។ លើសនេះទៀត ការផ្ដល់ការអនុញ្ញាតឲ្យចូលមើលយោបល់

---

[95] សំណុំរឿង ០០១-**F28** សាលដីកា *ឌុច* កថាខណ្ឌ ៧០៨។

[96] សហចៅក្រមរបាយការណ៍ស្ដីពីមុខងារនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ *របាយការណ៍ប្រឹក្សា៖ សកម្មភាពទាក់ទងនឹងជនរងគ្រោះរបស់ អ.វ.ត.ក កំឡុងដំណាក់កាលសេសសល់ ("របាយការណ៍ចៅក្រមរបាយការណ៍")* ទំព័រ ២៤-២៥។

[97] អត្ថបទស្រាវជ្រាវដោយ Caitlin McCaffrie, Somaly Kum, Daniel Mattes, Lia Tay ក្រោមចំណងជើងថា *ដូច្នេះយើងអាចដឹងពីអ្វីដែលបានកើតឡើង៖ សក្ខានុពលអប់រំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* បោះពុម្ពដោយ Stanford: មជ្ឈមណ្ឌលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ នៅសាកលវិទ្យាល័យ Stanford ឆ្នាំ២០១៨ ("ដូច្នេះយើងអាចដឹងពីអ្វីដែលបានកើតឡើង") ទំព័រ១៨-២១, ៣២-៣៦។ អត្ថបទស្រាវជ្រាវដោយ Phuong Pham, Patrick Vinck, Mychelle Balthazard, Sokhom Hean, Eric Stover មានចំណងជើងថា *ដូច្នេះយើងនឹងមិនអាចបំភ្លេចបាន៖ ការស្ទង់មតិផ្អែកលើប្រជាជនលើអាកប្បកិរិយាអំពីការកសាងសង្គមឡើងវិញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*។ Berkeley: មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ឆ្នាំ២០០៩ ទំព័រ២៦-២៧, ៤០-៤២, ៤៦-៤៧។ អត្ថបទស្រាវជ្រាវដោយ Phuong Pham, Patrick Vinck, Mychelle Balthazard, Sokhom Hean *បន្ទាប់ពីការកាត់ក្ដីលើកដំបូង៖ ការស្ទង់មតិផ្អែកលើប្រជាជនស្ដីពីចំណេះដឹង និងការយល់ឃើញអំពីយុត្តិធម៌ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*។ Berkeley: មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ឆ្នាំ២០១១ ទំព័រ៣១-៣២។

[98] ដូច្នេះយើងអាចដឹងពីអ្វីដែលបានកើតឡើង ទំព័រ២០-២១។

[99] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។

គតិយុត្តិ និងសាលក្រមដែលមានសំអាងហេតុ សារណាដែលមានអំណះអំណាងអង្គច្បាប់ និងអង្គហេតុបែបនីតិវិធីដែលមានការគាំទ្រត្រឹមត្រូវ និង ឯកសារដែលមានការយល់ដឹងជ្រៅជ្រះអំពីការអនុវត្តបែបស៊ើបអង្កេត ដែលផ្តោតលើការប្រមូលភស្តុតាងដែលអាចជឿជាក់បាន នឹងជួយពង្រឹងគុណភាពយុត្តិធម៌ ដែលបានផ្តល់ដោយប្រព័ន្ធច្បាប់ជាតិកម្ពុជា។ ចៅក្រមរបាយការណ៍បានគូសបញ្ជាក់ថា ការផ្ទេរចំណេះដឹង និងការកសាងសមត្ថភាព គឺជាសេចក្តីប្រាថ្នាផ្ទាល់របស់តុលាការកូនកាត់ទាំងអស់[100] ហើយចៅក្រមរបាយការណ៍បានលើកទឹកចិត្តគម្រោងកេរដំណែល ដែលទាក់ទងនឹងការផ្ទេរចំណេះដឹងនៅក្នុងវិស័យច្បាប់ រួមទាំងការបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា និងមេធាវីផង[101]។

40. សរុបមក សហព្រះរាជអាជ្ញាយល់ឃើញថា គួរផ្តោតការយកចិត្តទុកដាក់លើលក្ខណៈ និងខ្លឹមសារនៃឯកសារដាច់ដោយឡែកនីមួយៗ ដើម្បីកំណត់ថាតើការបន្តការសម្ងាត់ ឬការកោសលុបចាំបាច់ឬទេ ជាជាងអង្គហេតុដែលថាវាត្រូវបានដាក់ក្នុងសំណុំរឿង ០០២ ក្នុងអំឡុងពេលកិច្ចស៊ើបសួរ។ ផលប្រយោជន៍សាធារណៈដ៏លើសលុបតម្រូវឲ្យមានការពង្រីកតម្លាភាពជាអតិបរមា ក្នុងការផ្តល់លទ្ធភាពឲ្យមានការចូលមើលបណ្ណសាររបស់ អ.វ.ត.ក និងដើម្បីបង្កើនភាពត្រឹមត្រូវតាមច្បាប់នៃកិច្ចដំណើរការនីតិវិធី និងការរកឃើញនានារបស់ខ្លួន។ ដូច្នេះ ការបន្សល់ទុកនូវកេរដំណែលផ្នែកយុត្តិសាស្រ្ត ប្រវត្តិសាស្រ្ត និងការអប់រំដ៏រឹងមាំ ដែលចូលរួមចំណែកដល់ការផ្សះផ្សាជាតិ គឺជាការចាំបាច់។

## ខ. ការសង្កេតលើគោលការណ៍ណែនាំដែលបានស្នើឡើង

41. អ.ជ.ត.ក ស្វែងរកឲ្យមានការដាក់សេចក្តីសន្និដ្ឋានជាក់លាក់ស្តីពីគោលការណ៍ណែនាំដែលបានស្នើឡើង និងឯកសារនានាដែលមានរៀបរាប់នៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ៥.១(ក), (ខ), (គ) និង (ច)[102]។ ដើម្បីចៀសវាងភាពច្រំដែល សហព្រះរាជអាជ្ញាលើកយកបញ្ហាទាំងនេះមកពិភាក្សារួមគ្នា។ នៅក្នុងដំណាក់កាលនៃដំណើរការធ្វើចំណាត់ប្រភេទឡើងវិញនេះ ការពិភាក្សារបស់សហព្រះរាជអាជ្ញាអំពីប្រភេទ និងអនុប្រភេទជាក់លាក់របស់ឯកសារ មានបំណងជួយដល់ អ.ជ.ត.ក ប៉ុន្តែមិនល្អិតល្អន់នោះទេ និងត្រូវបានធ្វើឡើងដោយគ្មាន

---

[100] របាយការណ៍របស់ចៅក្រមរបាយការណ៍ ទំព័រ ២៥។

[101] របាយការណ៍របស់ចៅក្រមរបាយការណ៍ ទំព័រ ២៨។

[102] ឯកសារ **F71/1/1** សំណើសុំឲ្យដាក់សារណា កថាខណ្ឌ ៣-៥។

ការលម្អៀងទៅរកសេចក្តីសន្និដ្ឋានក្រោយរបស់ខ្លួន ទាក់ទងនឹងឯកសារ ឬប្រភេទនៃឯកសារ ជាក់លាក់នោះទេ[103]។

## *មាត្រា ៥.១(ក) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា*

42. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការធ្វើចំណាត់ប្រភេទតាមវិធាន ៥៤ ពីដំបូងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន លែងចាំបាច់ទៀតហើយ ប៉ុន្តែត្រូវមានការកោសលុបតិចតួចដែលចាំបាច់ដើម្បីការពារព័ត៌មានរសើប ដែលបានពិភាក្សានៅកន្លែងផ្សេងទៀត[104]។ តាមពិត វិសាលភាពនៃសំណុំរឿង ០០២ ដូចបាន បង្ហាញដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ត្រូវបានធ្វើឱ្យទៅជាសាធារណៈតាំងពីក្នុងដីកាដំណោះស្រាយមកម្ល េះ[105] វិសាលភាពនៃការជំនុំជម្រះ និងសាលក្រមក្នុងសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ ខ្លួនវាផ្ទាល់ និងនៅក្នុងចំណុចស្នូលនៃមូលដ្ឋានជាច្រើននៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ របស់ ខៀវ សំផន។ ឯកសារដូចគ្នានេះជាទូទៅត្រូវបានធ្វើឱ្យទៅជាសាធារណៈដោយ អ.ប.ជ ក្នុងសំណុំរឿង ០០៣[106] សំណុំរឿង ០០៤/១[107] សំណុំរឿង ០០៤/២[108] និង សំណុំរឿង ០០៤[109]។

---

[103] ដូចបានប្រមើលដោយ អ.ជ.ត.ក ក្នុងឯកសារ **F71/1/1** សំណើសុំឱ្យដាក់សារណាការ កថាខណ្ឌ ២។

[104] ជាពិសេស ការកោសលុបអាចចាំបាច់ក្នុងការការពារ ជាឧទាហរណ៍ ព័ត៌មានរសើបទាក់ទងនឹងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត ក៏ដូចជា ជនរងគ្រោះនៃអំពើហិង្សាលើផ្លូវភេទ និងយ៉ែនឌ័រ ក្នុងករណីដែលបញ្ហាទាំងនេះមិនមែនជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ក៏ដូចជាព័ត៌មានដែលអាចបង្កគ្រោះថ្នាក់ដល់សន្តិសុខរបស់ជនរងគ្រោះ ឬសាក្សី។ *សូមមើលបន្ថែមទៀត យោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

[105] ឯកសារ **D427** ដីកាដំណោះស្រាយ។

[106] សំណុំរឿង ០០៣-**D274** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ មានចំណងជើងថា "ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារក្នុងសំណុំរឿង ០០៣" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ("អនុស្សរណៈ អ.ប.ជ ស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ") កថាខណ្ឌ ២។ សំណុំរឿង ០០៣-**D274.1** ឧបសម្ពន្ធ លេខរៀងទី ២-៦ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឧបសម្ព័ន្ធរបស់វា) ៧៧ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) ១១៧ (ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ) ១១៨ (ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ)។

[107] សំណុំរឿង ០០៤/១-**D317** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះមានចំណងជើងថា "ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារក្នុងសំណុំរឿង ០០៤/១" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ កថាខណ្ឌ ២។ សំណុំរឿង ០០៤/១-**D317.1** ឧបសម្ពន្ធ លេខរៀងទី១-៥ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឧបសម្ព័ន្ធរបស់វា) ១៥, ៣៥, ៧៩, ៨៤ (ដីកាសន្និដ្ឋាន

## *មាត្រា ៥.១(ខ)៖ សំណុំឯកសារដែលទទួលបាន និងភស្តុតាងដែលផ្តល់ឱ្យនៅដំណាក់កាលស៊ើបអង្កេតរបស់តុលាការ*

43. នេះគឺជាប្រភេទទូលំទូលាយដែលគ្របដណ្តប់ស្ទើតែកិច្ចស៊ើបសួរទាំងមូលរបស់តុលាការ។ ដើម្បីជួយដល់ អ.ជ.ត.ក បានល្អបំផុត សហព្រះរាជអាជ្ញាបានបំបែកប្រភេទនេះជាអនុប្រភេទ ដែលខ្លួនធ្វើការសង្កេតដាច់ដោយឡែកពីគ្នា។ ដោយសារតែមានភាពជាន់គ្នារវាងមាត្រា ៥.១(ខ) និងមាត្រា ៥.១(គ)-(ជ) សហព្រះរាជអាជ្ញាលើកឡើងចំណុចទាំងនោះមួយចំនួននៅក្នុងចំណងជើងដាច់ដោយឡែកពីគ្នាខាងក្រោម។

44. តាមការសង្កេតជាទូទៅ សហព្រះរាជអាជ្ញាជំរុញឱ្យ អ.ជ.ត.ក លុបចោលចំណុច៤(ក)(vi) នៃគោលការណ៍ណែនាំដែលបានស្នើឡើង[110]។ ពួកគាត់កត់សម្គាល់ថា គោលការណ៍ណែនាំដូចគ្នានេះត្រូវបានប្រើក្នុងអំឡុងពេលការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ របស់ អ.ជ.ត.ក ក្នុងឆ្នាំ២០១២[111] ប៉ុន្តែយល់ឃើញថា ការធ្វើចំណាត់ប្រភេទឯកសារក្នុងសំណុំរឿង អ.វ.ត.ក មួយផ្សេងទៀតលែងមានសារសំខាន់ដូចក្នុងឆ្នាំ២០១២ ទៀតហើយ ដែលនៅពេលនោះកិច្ចដំណើរការនីតិវិធី រួមទាំងកិច្ចស៊ើបសួរសម្ងាត់ កំពុងបន្ត[112]។ នៅពេលចេញសាលដីកាលើបណ្តឹងសាទុក្ខ

---

បញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) ៩៤ (ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ) ៩៥ (ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ)។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-**D304/6/4** សេចក្តីសម្រេចរបស់ អ.ប.ជ លើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ៣២។

[108] សំណុំរឿង ០០៤/២-**D360/47** & **D359/38** សេចក្តីសម្រេចស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២-**D360/47.2** ឧបសម្ព័ន្ធ លេខរៀងទី ១-៤, ៤៦ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឧបសម្ព័ន្ធរបស់វា) ២៧, ៣៤, ៦៨ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) ៥៨, ៦០ (ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ)។

[109] សំណុំរឿង ០០៤-**D387** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះមានចំណងជើងថា "ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ កថាខណ្ឌ២។ សំណុំរឿង ០០៤-**D387.1** ឧបសម្ព័ន្ធលេខរៀងទី១-៥ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឧបសម្ព័ន្ធរបស់វា) ១៣, ៣៣, ៩៧, ១០២ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) ១៦៨ (ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ)។

[110] **F71/1/1** សំណើសុំឱ្យដាក់សារណា កថាខណ្ឌ ៤(ក)(vi)។

[111] *សូមមើល* សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៧(ខ)(iii)។

[112] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៦។

ក្នុងសំណុំរឿង ០០២/០២ រាល់កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ទាំងអស់នឹងត្រូវបានបញ្ចប់ ហើយ មូលហេតុរក្សាការសម្ងាត់ក្នុងករណីជាច្រើននឹងលែងមានសុពលភាពទៀតហើយ។ ក្នុងករណីដែល មានហេតុផលបន្តទៀតសម្រាប់រក្សាការសម្ងាត់ ឬបង្កើតសំណៅកោសលុបនោះ ជាការពិតចំណុច ទាំងនេះត្រូវតែគោរពតាម។ ប៉ុន្តែ*អង្គហេតុតែមួយគត់*ដែលថា ឯកសារមួយត្រូវបានចាត់ថ្នាក់ថាជា ឯកសារសម្ងាត់នៅក្នុងសំណុំរឿងមួយផ្សេងទៀត វាមិនមែនជាមូលហេតុរបស់វាផ្ទាល់ក្នុងការក្សា ឬដាក់ការធ្វើចំណាត់ប្រភេទសម្ងាត់នោះទេ។ ការធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារនៅក្នុង សំណុំរឿង ០០៣, ០០៤/១, ០០៤/២ និង០០៤ គឺនៅមិនទាន់បានដោះស្រាយនៅឡើយ ហើយ ប្រសិនបើលក្ខណៈវិនិច្ឆ័យនេះនៅតែមាន នោះដំណើរការនេះនឹងទំនងជាវិលទៅវិលមក។

### i. ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ

45. ដោយមិនគិតថា ឯកសារទាំងនេះត្រូវបានទទួលយកជាភ័ស្តុតាងនៅឯសវនាការឬអត់នោះទេ[113] សហព្រះរាជអាជ្ញាយល់ថាមិនចាំបាច់ត្រូវរក្សាឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ[114]ខាងក្រោម នេះជាការសម្ងាត់បន្តទៀតនោះឡើយ៖

- សេចក្តីថ្លែងការណ៍ និងការប្រាស្រ័យទំនាក់ទំនងជាសាធារណៈនិងជាផ្លូវការ ដែលបានធ្វើដោយមេ ដឹកនាំកម្ពុជាប្រជាធិបតេយ្យ។
- កំណត់ហេតុនៃកិច្ចប្រជុំ រួមមាន តែមិនកំណត់ត្រឹមប៉ុណ្ណឹងទេ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈ កម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ("បកក") កិច្ចប្រជុំរបស់ក្រសួងនិងតាមប្រធានបទ (ដូចជា កិច្ចប្រជុំរបស់រដ្ឋមន្ត្រី និង ក្រសួងពាណិជ្ជកម្ម កិច្ចប្រជុំទាក់ទងនឹងសាធារណការ កិច្ចការ ក្នុងស្រុក សង្គមកិច្ច និងសុខាភិបាល) កិច្ចប្រជុំរបស់ថ្នាក់ដឹកនាំយោធា កិច្ចប្រជុំរបស់ "សភា តំណាងប្រជាជនកម្ពុជា" កិច្ចប្រជុំនៅក្នុងកិច្ចចចារសេដ្ឋកិច្ច/ពាណិជ្ជកម្ម និងមហាសន្និបាតរបស់ អ.ស.ប។

---

[113] ភ័ស្តុតាងដែលបានទទួលយកនៅពេលសវនាការសន្មតថាជាសាធារណៈ *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ ប្រភេទឯកសារ មាត្រា ៤(ឃ)។

[114] មិនកម្រិតត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ទេ ប៉ុន្តែរួមបញ្ចូលទាំងឯកសារមុន និងក្រោយ សម័យកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្នុងក្រុមទាំងនេះ រួមមានជាពិសេសឯកសារដែលទាក់ទងនឹងព័ត៌មានអំពី បកក និងគោលនយោបាយរបស់វា។

- លិខិតស្នាម បទបញ្ជា និងរបាយការណ៍នានាទៅវិញទៅមកពីមន្ត្រី បកក រួមបញ្ចូលទាំងសេចក្តីសម្រេច និងគោលការណ៍ណែនាំរបស់គណៈកម្មាធិការមជ្ឈិម បកក។
- ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ។
- អត្ថបទសារព័ត៌មាន រួមទាំង ទស្សនាវដ្តីរបស់ បកក អត្ថបទនិងរបាយការណ៍សារព័ត៌មាន ប្រតិចារឹកនៃការផ្សាយសំឡេងតាមវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ សេចក្តីប្រកាសព័ត៌មាននិងសេចក្តីថ្លែងការរបស់រដ្ឋាភិបាល ទូរលេខការទូត ឯកសារ អ.ស.ប និង របាយការណ៍របស់សេវាកម្មការផ្សាយព័ត៌មានបរទេស (FBIS)។ និង
- ផែនទី និងរូបថត។

46. ភាគច្រើននៃឯកសារទាំងនេះត្រូវបានបង្កើតឡើងភ្លាមៗមុន ឬក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយមានករណីលើកលែងខ្លះដូចបានកត់សំគាល់ខាងក្រោម សហព្រះរាជអាជ្ញាសូមជូនយោបល់ថា ជាទូទៅសូមធ្វើឲ្យឯកសារសម័យកម្ពុជាប្រជាធិបតេយ្យទាំងនេះ ទៅជាសាធារណៈ ដើម្បីបម្រើឲ្យគោលការណ៍នៃតម្លាភាព។ មានរយៈពេលជាង ៤០ ឆ្នាំ កន្លងមកហើយ ចាប់តាំងពីពេលដែលភាគច្រើនឯកសារទាំងនេះត្រូវបានបង្កើតឡើង ឯកសារទាំងនេះមានតម្លៃជាប្រវត្តិសាស្ត្រខ្ពស់ ប៉ុន្តែជាទូទៅ មិនមានព័ត៌មានដែលនាំឲ្យមានការរំលោភបំពានសិទ្ធិឯកជនរបស់បុគ្គលណាម្នាក់ឡើយ។ ការធ្វើឲ្យប្រាកដថាឯកសារសម័យកម្ពុជាប្រជាធិបតេយ្យនេះអាចឲ្យសាធារណជនមានសិទ្ធិចូលពិនិត្យមើលបាន គឺជាការអនុញ្ញាតឲ្យមនុស្សជំនាន់ក្រោយនិងអ្នកសិក្សាស្រាវជ្រាវបានយល់ដឹងកាន់តែប្រសើរអំពីប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍នានារបស់កម្ពុជាប្រជាធិបតេយ្យ និងអំពីបទចោទក្នុងសំណុំរឿង ០០២។ ទោះជាយ៉ាងណា ជាបញ្ហាទូទៅ ដែលរដ្ឋមួយ ឬស្ថាប័នអន្តរជាតិមួយ បានផ្តល់ឯកសារមកឲ្យ អ.វ.ត.ក ដោយយល់ច្បាស់ថា ពួកវានឹងមិនត្រូវបានបញ្ចេញជាសាធារណៈ ការព្រមព្រៀងបែបនេះគួរទទួលបានការគោរព។ អ.ជ.ត.ក មិនគួរធ្វើចំណាត់ប្រភេទឯកសារបែបទាំងនោះជាសាធារណៈទេ លុះត្រាតែ និងរហូតទាល់តែអ្នកផ្តល់ឯកសារបានផ្តល់ការអនុញ្ញាតឲ្យដាក់ឯកសារទាំងនេះជាសាធារណៈ[115]។

47. សហព្រះរាជអាជ្ញាសន្និដ្ឋានថា សម្ភារសម័យកម្ពុជាប្រជាធិបតេយ្យ តម្រូវឲ្យមានការគ្រប់គ្រងដោយប្រយ័ត្នប្រយែង ដោយសារឯកសារទាំងនោះ មានប្រភពមកពីមន្ទីរសន្តិសុខនានារបស់កម្ពុជាប្រជាធិប

---

[115] ដូចបានប្រមើលនៅក្នុងគោលការណ៍ណែនាំដែលបានស្នើឡើង ៤(ង)។

តេយ្យ គឺពីមន្ទីរ ស-២១ និងក្រាំងតាចាន់ ជាចំបង។ សំណុំរឿង ០០២ មានបញ្ជីឈ្មោះអ្នកទោស ប្រវត្តិរូប ចម្លើយសារភាព និងសៀវភៅកំណត់ហេតុ រាប់ពាន់ពីស្ថាប័នទាំងនេះ។ សហព្រះរាជអាជ្ញាសូមផ្តល់សេចក្តីសង្កេត ដូចតទៅ៖

48. **បញ្ជីឈ្មោះអ្នកទោស៖** ឯកសារទាំងនេះ រួមមានទាំងបញ្ជីអ្នកទោសដែលត្រូវបានសួរចម្លើយ និង/ឬ សម្លាប់នៅតាមមន្ទីរសន្តិសុខនានារបស់កម្ពុជាប្រជាធិបតេយ្យ ព្រមទាំងរបាយការណ៍រដ្ឋបាលផ្សេងៗទៀត ទាក់ទងនឹងអ្នកទោស។ ដោយបានរៀបចំឡើងក្នុងពេលវេលាធម្មតានៃការគ្រប់គ្រងក្បាលម៉ាស៊ីនសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ត្រាទាំងនេះមិនមែនជាផលិតផលនៃការធ្វើទារុណកម្មទេ ដូច្នេះអាចធ្វើឱ្យទៅជាសាធារណៈដោយសុវត្ថិភាពបាន។

49. សហព្រះរាជអាជ្ញាកត់សម្គាល់ថា គោលការណ៍ណែនាំដែលបានស្នើឡើង ៤(ក)(iv) ទាក់ទងនឹង "ឈ្មោះ [...] ជនរងគ្រោះមិនមែនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី"[116] ត្រូវបានបញ្ចូលតាំងពីមានគោលការណ៍ណែនាំក្នុងសំណុំរឿង ០០១[117]។ គោលការណ៍ណែនាំដូចបានស្នើឡើងនេះ មិនសមាមាត្រនឹងគ្នាយ៉ាងធំធេង។ ដោយសារពាក្យថា "ជនរងគ្រោះ" មិនត្រូវបានកំណត់និយមន័យ ដូច្នេះអត្ថន័យរបស់ពាក្យនៅក្នុងបរិបទនេះគឺមិនច្បាស់លាស់ទេ និងមានសក្តានុពលក្នុងការពង្រីកអត្ថន័យមិនត្រឹមត្រូវ[118]។ គោលការណ៍ណែនាំនេះ គួរមាន*ជាអាទិ៍* ការកោសលុបឈ្មោះគ្រប់ជនរងគ្រោះ រួមទាំងជនរងគ្រោះនៃការជម្លៀសដោយបង្ខំគ្រប់រូប (ជាសមាមាត្រមួយផ្នែកធំនៃចំនួនប្រជាប្រជនក្នុងពេលនោះ) ចេញពីឯកសារទាំងអស់នៅក្នុងសំណុំរឿង អ.វ.ត.ក រួមទាំង ជាឧទាហរណ៍ អ្នកទាំងឡាយដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកទោស ស-២១ ទាំងអស់។ ប៉ុន្តែបើធ្វើដូច្នេះ វាជាការកំហិតមួយមិនចាំបាច់ និងមិនសមាមាត្រទៅលើសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាននេះ។ មិនមានករណីយុត្តិ

[116] ឯកសារ **F71/1/1** សំណើសុំឱ្យដាក់សារណា កថាខណ្ឌ ៤(ក)(iv)។

[117] *សូមមើល* សំណុំរឿង ០០១-ឯកសារ **F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃសំណុំរឿង ០០១ កថាខណ្ឌ ៧(ខ)(i)។

[118] សន្ទានុក្រមវិធានផ្ទៃក្នុង កំណត់និយម "ជនរងគ្រោះ" ថា "រូបបុគ្គល ឬ នីតិបុគ្គល ដែលបានទទួលរងនូវព្យសនកម្មពីការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក"។ សហព្រះរាជអាជ្ញាបានកត់សម្គាល់លើពាក្យ "ជនរងគ្រោះ" នេះគឺមានន័យស្រដៀងគ្នាទៅនឹងការបកស្រាយទូលំទូលាយផងដែរ ហើយក៏មិនកម្រិតត្រឹមបុគ្គលដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាស់នៅចំពោះមុខ អ.វ.ត.ក ឡើយ (របាយការណ៍របស់សហអ្នករាយការណ៍ពិសេស ទំព័រ ១១) និងថា "សមាជិកសង្គមគ្រប់រូបសុទ្ធតែទទួលរងការប៉ះពាល់ប្រហាក់ប្រហែលគ្នា ក្នុងពេលជម្លោះដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ" (របាយការណ៍របស់សហអ្នករាយការណ៍ពិសេស ទំព័រ ២៤)។

សាស្ត្រដោយផ្ទាល់ចំពោះការកំហិតទូលំទូលាយណាមួយដូច្នេះទេពីមុនមក ព្រោះថាជាឧទាហរណ៍ ឈ្មោះជនរងគ្រោះនៃការសម្លាប់រង្គាលក្នុងសង្គ្រាមលោកលើកទី២ ក៏មិនត្រូវបានដកចេញជាប្រព័ន្ធជាសាធារណៈនោះដែរ។ សហព្រះរាជអាជ្ញាសូមជូនយោបល់ថា ក្នុងករណីណាដែលចាំបាច់ប៉ុណ្ណោះ ជាឧទាហរណ៍ ត្រង់ចំណុចដែលវាតម្រូវដោយវិធានការការពារ ឬដើម្បីការពារជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងឈ្មោះជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ ដែលឈ្មោះរបស់ជនរងគ្រោះគួរត្រូវបានកោសលុប[119]។

50. **ចម្លើយសារភាព៖** អ.ជ.ត.ក និង អ.ជ.ស.ជ បានរកឃើញថា ចម្លើយសារភាពរបស់អ្នកទោសមន្ទីរសន្តិសុខ ជាពិសេសមកពីមន្ទីរ ស-២១ គឺត្រូវបានសន្មតថា ត្រូវបានផលិតឡើងក្រោមអំពើទារុណកម្ម ឬក្រោមការគំរាមកំហែងនៃការធ្វើទារុណកម្ម[120]។ ឯកសារទាំងនេះរួមបង្កើតបានជាភ័ស្តុតាងនៃការសួរចម្លើយ និងការធ្វើទារុណកម្ម ដែលមានលក្ខណៈសម្របសម្រួល និងជាប្រព័ន្ធ លើមនុស្សដែលរបបកម្ពុជាប្រជាធិបតេយ្យបានចាត់ទុកថាជាខ្មាំង។ សហព្រះរាជអាជ្ញាសូមរម្លឹកអំពីសារសំខាន់ជាពិសេសនៃការធានាឲ្យប្រាកដថា ភ័ស្តុតាងនៃឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម បានទៅដល់សាធារណជន ដើម្បីលើកកម្ពស់ដល់ការសិក្សា និងកិច្ចពិភាក្សាអំពីអំពើទារុណកម្ម និងការហាមឃាត់ចំពោះអំពើនេះ និងឋានៈរបស់វាជានិយាមមួយដែលត្រូវតែអនុវត្ត ឬ *ច្បាប់ចាប់បង្ខំ (jus cogens)* ក្នុងគោលបំណងធ្វើឲ្យរាងចាលកុំឲ្យកើតឡើងនូវអំពើនោះជាថ្មីទៀត[121]។

---

[119] *សូមមើលយោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

[120] ឯកសារ **F26/12** សេចក្ដីសម្រេចស្ដីពីការជំទាស់ទៅនឹងបញ្ជីឯកសារ៖ សំអាងហេតុពេញលេញ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៥៦-៥៧ (តែ ស-២១ ប៉ុណ្ណោះ)។ ឯកសារ **E350/8** សេចក្ដីសម្រេចស្ដីពីភ័ស្តុតាងទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ៧៩ (ស-២១ និងមន្ទីរសន្តិសុខផ្សេងៗទៀត)។

[121] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្ដី *Furundžija*, ក្នុងវាក្យខ័ណ្ឌមួយដែលបានដកស្រង់ដោយមានការយល់ព្រមពីសភាចក្រភពអង់គ្លេស (UK House of Lords) ក្នុងរឿងក្ដី *Pinochet* (*R. ទល់នឹង Bartle និងស្នងការនគរបាលក្រុង និងភាគីតែម្ខាងផ្សេងទៀតរបស់ Pinochet; R. ទល់នឹង Evans និងម្នាក់ទៀត និងស្នងការនគរបាលក្រុង និងភាគីតែម្ខាងផ្សេងទៀតរបស់ Pinochet,* ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ Lord Browne-Wilkinson) សង្កត់ធ្ងន់អំពីប្រភេទទារុណកម្ម*តាមច្បាប់ចាប់បង្ខំ* ថា៖ "ដោយសារសារសំខាន់នៃតម្លៃដែលខ្លួនការពារ [ការហាមឃាត់អំពើទារុណកម្ម] បានវិវឌ្ឍន៍ទៅជានិយាមចាប់បង្ខំ ឬ*ច្បាប់ចាប់បង្ខំ* មានន័យថា ជានិយាមមួយដែលទទួលបានឋានៈខ្ពស់នៅក្នុងឋានានុក្រមអន្តរជាតិ ជាងច្បាប់សិទ្ធិសញ្ញា និងក៏ខ្ពស់ជាងសូម្បីតែ "វិធានទម្លាប់'ធម្មតា'។ [...] ច្បាស់ណាស់ថា លក្ខណៈនៃ*ច្បាប់ចាប់បង្ខំ* នៃការហាមឃាត់ប្រឆាំងនឹងអំពើទារុណកម្មបានបញ្ជាក់យ៉ាងច្បាស់អំពីការយល់ដឹងមួយថា ការហាមឃាត់នោះបច្ចុប្បន្ន បានក្លាយជាបទដ្ឋានគ្រឹះដ៏រឹងមាំមួយរបស់សហគមន៍អន្តរជាតិ។ ជាងនេះទៅទៀត ការហាមឃាត់នេះត្រូវបានរចនាឡើងដើម្បីបង្កើតឲ្យមានប្រសិទ្ធិភាពខុសៗគ្នាដែលក្នុងនោះវាបញ្ចេញសញ្ញាប្រាប់ដល់សមាជិកសហគមន៍អន្តរជាតិទាំងអស់ និងបុគ្គលគ្រប់រូបផ្សេងទៀតដែលមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងលើការហាមឃាត់

51. ហេតុដូចនេះ ភ័ស្តុតាងនៃអំពើទារុណកម្មដោយរបបកម្ពុជាប្រជាធិបតេយ្យ គឺមានតម្លៃជាប្រវត្តិសាស្ត្រ និងអប់រំខ្ពស់។ ទោះជាយ៉ាងណា តម្លៃក្នុងការធ្វើឲ្យភ័ស្តុតាងនេះអាចរកបានជាសាធារណៈ ក៏ត្រូវតែថ្លឹងថ្លែង ធៀបនឹងគ្រោះថ្នាក់ជាយថាហេតុដែលអាចកើតមានចំពោះសាច់ញាតិ និងអ្នកនៅរស់ ដោយសារការបង្ហាញអត្តសញ្ញាណ និង/ឬ ព័ត៌មានបែបរសើបជាសាធារណៈ[122]។ អាស្រ័យដោយមូលហេតុនេះ សហព្រះរាជអាជ្ញា សូមផ្តល់អនុសាសន៍ថា ព័ត៌មានទាំងនោះត្រូវកោសលុបចេញពីចម្លើយសារភាពមន្ទីរសន្តិសុខ។ ក្នុងករណីដែលព័ត៌មាននេះ ត្រូវបានធ្វើទៅជាសាធារណៈរួចហើយកន្លងមក[123] អ.ជ.ត.ក គប្បីពិចារណាធ្វើចំណាត់ប្រភេទឡើងវិញទៅជាសម្ងាត់ (ដោយការកោសលុប) នូវព័ត៌មាននោះ។ ការកោសលុបលើចម្លើយសារភាព ជាជាងការធ្វើឲ្យពួកវាទៅជាសម្ងាត់ទាំងស្រុង ជួយលើកកម្ពស់ដល់កេរដំណែលផ្នែកប្រវត្តិសាស្ត្រ និងផ្នែកអប់រំ ដោយបន្សល់ទុកនូវព័ត៌មានមានតម្លៃ ដូចជាចំណាររបស់ ឌុច និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត អាចត្រូវបានចូលមើលជាសាធារណៈ។ សហព្រះរាជអាជ្ញាផ្តល់អនុសាសន៍ឲ្យធ្វើចំណាត់ប្រភេទចម្លើយសារភាពទាំងនេះទៅជាសម្ងាត់ រហូតទាល់តែការធ្វើការកោសលុបបែបនោះអាចធ្វើទៅបាន។

52. ទាក់ទងនឹងចំណុចនេះ សហព្រះរាជអាជ្ញាមានការយល់ដឹងអំពីគោលនយោបាយរបស់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (“TSGM”) ដែលមានការថ្លឹងថ្លែងអំពីផលប្រយោជន៍ប្រគួតប្រជែងផ្សេងៗគ្នា ក្នុងការធ្វើឲ្យឯកសារជាច្រើននៅក្នុងបណ្ណសាររបស់ខ្លួនអាចរកបានជាសាធារណៈ[124] ប៉ុន្តែ

---

ការធ្វើទារុណកម្ម ដែលគ្មាននរណាម្នាក់អាចដាកចេញបានជាដាច់ខាត” (*Furundžija*, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៤៣-១៤៦, ១៥៤ ដកស្រង់ត្រង់កថាខណ្ឌ ១៥៣-១៥៤)។

[122] ឧទាហរណ៍ ចម្លើយសារភាពមានឈ្មោះ និងព័ត៌មានលម្អិតកំណត់អត្តសញ្ញាណផ្សេងទៀត របស់ជនក្បត់ដែលគេចោទប្រកាន់ដែលត្រូវបានធ្វើឡើងក្រោយការធ្វើទារុណកម្ម។

[123] ចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ និងក្រាំងតាចាន់ ដែលកំណត់អត្តសញ្ញាណដោយសហព្រះរាជអាជ្ញាជាសាធារណៈ ត្រូវបានរៀប់រាប់ក្នុង **ឧបសម្ព័ន្ធ ក** ៖ ចម្លើយសារភាពមន្ទីរសន្តិសុខ ប្រវត្តិរូបអ្នកទោស និងសៀវភៅកត់ត្រាដែលបានធ្វើចំណាត់ប្រភេទជាសាធារណៈ។

[124] *សូមមើល* គោលនយោបាយស្តីពីសិទ្ធិចូលមើលឯកសាររបស់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (“គោលនយោបាយចូលមើលរបស់ TSGM”) កថាខណ្ឌ ១ (“បណ្ណសាររបស់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ផ្តល់សិទ្ធិចូលមើលឯកសារ ក) ដល់សាធារណជនខ្មែរ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្រុមគ្រួសារ និងជនរងគ្រោះនៃមន្ទីរស-២១ និងអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ អំពីចំណេះដឹងនៃអត្ថិភាពបណ្ណសារមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងអំពីប្រភេទឯកសារខុសៗគ្នាដែលមាននៅក្នុងបណ្ណសារនោះ; ខ) ដើម្បីបង្កើនឱកាសដល់ប្រជាជនបានដឹងថាតើ សាច់ញាតិ/មិត្តភក្តិដែលបាត់ខ្លួនបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ដែរឬទេ”) កថាខណ្ឌ ៥។

ក៏មានការការពារចំពោះព័ត៌មានរសើបកម្រិតខ្ពស់ រួមទាំង ព័ត៌មានទទួលបានដោយការធ្វើទារុណកម្ម ផងដែរ[125]។ តាមការស្រាវជ្រាវតាមអនឡាញមួយអំពីឈ្មោះជនជាប់ឃុំឃាំងម្នាក់ បានរកឃើញបញ្ជីមួយដែលមានឯកសារកាលប្រវត្តិទាំងអស់ទាក់ទងនឹងជនជាប់ឃុំឃាំងរូបនោះ ប៉ុន្តែអ្នកស្រាវជ្រាវមិនអាចមើលខ្លឹមសារនៃចម្លើយសារភាព ឬ ប្រវត្តិរូប(ភាគច្រើន)បានទេ។ អ្នកស្រាវជ្រាវ ត្រូវបានដាស់តឿនអំពីអត្ថិភាពនៃកំណត់ហេតុដូច្នេះ ប៉ុន្តែគាត់ត្រូវដាក់ពាក្យសុំការអនុញ្ញាត ឬបំពេញនូវលក្ខខណ្ឌតម្រូវដែលបានកំណត់នៅក្នុងគោលនយោបាយស្តីពីលទ្ធភាពចូលមើលឯកសាររបស់សារមន្ទីរ មុនគាត់ត្រូវបានអនុញ្ញាតឱ្យមើលខ្លឹមសារទាំងនោះ[126]។

53. **ប្រវត្តិរូប៖** សហព្រះរាជអាជ្ញាក៏សូមផ្តល់អនុសាសន៍ថា ព័ត៌មានកំណត់អត្តសញ្ញាណនៅក្នុងប្រវត្តិរូបដែលប្រមូលបាននៅមន្ទីរ ស-២១ និងនៅមន្ទីរសន្តិសុខផ្សេងៗទៀត ក៏ត្រូវរក្សាស្ថានភាពជាសម្ងាត់របស់វាដដែល ហើយប្រសិនបើប្រវត្តិរូបណាត្រូវបានធ្វើឱ្យទៅជាសាធារណៈទាំងមូលរួចហើយកន្លងមក[127] នោះ អ.ជ.ត.ក គប្បីពិចារណាធ្វើចំណាត់ថ្នាក់ឡើងវិញនូវព័ត៌មាននេះ (ដោយធ្វើការកោសលុប)។

---

[125] សារមន្ទីរ TSGM ថ្លែងនៅលើវិបសាយរបស់ខ្លួនថា "ព័ត៌មានដែលមាននៅក្នុងឯកសារជាច្រើនទាំងនេះ ត្រូវគេយកបានតាមរយៈការធ្វើទារុណកម្ម ឬក្រោមការគំរាមកំហែងនៃការធ្វើទារុណកម្ម។ ជាវិបាក មតិយោបល់ ឬសេចក្តីថ្លែងណាមួយដែលបានបញ្ជាក់នៅក្នុងនោះ ត្រូវតែប្រព្រឹត្តក្នុងឆន្ទានុសិទ្ធិខ្ពស់បំផុត និងមិនត្រូវទទួលយកជាអង្គហេតុ ហើយមិនត្រូវយកជាភ័ស្តុតាងនៅក្នុងតុលាការអនុលោមតាមគោលការណ៍ច្បាប់ ក្រោមអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ឡើយ។ [TSGM] មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ ឬ ការពឹងផ្អែក លើមតិយោបល់ របកគំហើញ និងទិន្នន័យនៅក្នុងឯកសារទាំងនេះឡើយ"។ *សូមមើល* http://archives.tuolsleng.gov.kh/documents, ត្រង់សេចក្តីថ្លែងអំពីការលះបង់សិទ្ធិ។

[126] *សូមមើល* គោលនយោបាយស្តីពីសិទ្ធិចូលមើលឯកសាររបស់ កថាខណ្ឌ ៤, ៦, ៧ ("ប្រភេទព័ត៌មាននៅក្នុងបណ្ណសាររបស់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដូចតទៅ ដែលអាចរកបានជាសាធារណៈ តាមរយៈវិបសាយរបស់សារមន្ទីរ៖ ក) ព័ត៌មានពិស្តារជាមូលដ្ឋាន (metadata) អំពីឯកសារនីមួយៗដែលមាននៅក្នុងបណ្ណសារ រួមទាំង ប្រវត្តិរូប និងចម្លើយសារភាព ខ) ឈ្មោះអ្នកជាប់ឃុំឃាំងទាំងអស់ ជាមួយនឹងព័ត៌មានអត្តសញ្ញាណបន្ថែម គ) រូបថតរបស់អ្នកជាប់ឃុំឃាំងទាំងអស់ ដោយមានឬគ្មាន ឈ្មោះ (សូមមើលករណីលើកលែង ត្រង់ផ្នែក III នៃគោលនយោបាយនេះ) [...] ឃ) រូបភាពឯកសារនៃប្រវត្តិរូបជាក់លាក់របស់អ្នកជាប់ឃុំឃាំងដែលគេស្គាល់ភាគច្រើន (ឧ. ហួត បុប្ផាណា ជាដើម) កថាខណ្ឌ ៦។ ប្រភេទព័ត៌មានដែលមានការដាក់កំហិតក្នុងការចូលមើល រួមមាន: ក) រូបភាពឯកសារប្រវត្តិរូប ខ) រូបភាពឯកសារចម្លើយសារភាព") [...] កថាខណ្ឌ ៧។ IV សំណើសុំព័ត៌មាន" ព័ត៌មានដែលហាមឃាត់អាចចូលមើលបានដោយចំនួនមនុស្សមានកម្រិត ដូចជា សាច់ញាតិ និងមិត្តភក្តិរបស់អ្នកជាប់ឃុំ និងអ្នកស្រាវជ្រាវ។)។

[127] *សូមមើល* **ឧបសម្ព័ន្ធ ក៖** ចម្លើយសារភាពមន្ទីរសន្តិសុខ ប្រវត្តិរូបអ្នកទោស និងសៀវភៅកត់ត្រាដែលបានធ្វើចំណាត់ប្រភេទជាសាធារណៈ។

54. **សៀវភៅកំណត់ហេតុ៖** កំណត់ហេតុទាំងនេះ រួមមាន កំណត់ត្រារបស់អ្នកសួរចម្លើយតាមមន្ទីរសន្តិសុខ ដែលធ្វើឡើងក្នុងវគ្គរៀនសូត្រផ្នែកមនោគមវិជ្ជានិងរៀបរាប់លម្អិតអំពីខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកទោស។ កំណត់ហេតុទាំងនេះ ក៏បង្កើតបានជាភស្តុតាងដ៏សំខាន់ស្តីពីអំពើទារុណកម្មផងដែរ ដោយសារវាកំណត់អំពីបច្ចេកទេសនៃការសួរចម្លើយខ្លាំង ក្នុងវគ្គរៀនសូត្ររបស់កម្ពុជាប្រជាធិបតេយ្យ និងពាក់ព័ន្ធនឹងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តរបស់ បកក ឬកិច្ចពិភាក្សាអំពីគោលនយោបាយរបស់ថ្នាក់ដឹកនាំ បកក។ ដូចមូលហេតុដែលបានគូសបញ្ជាក់ទាក់ទងនឹងប្រវត្តិរូប និងចម្លើយសារភាពដែលបានបង្ហាញរួចហើយដែរ សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ឱ្យបន្តភាពសម្ងាត់ ឬធ្វើចំណាត់ថ្នាក់ឡើងវិញមកជាសម្ងាត់[128] ចំពោះព័ត៌មានដែលនាំឱ្យដល់ការបង្ហាញអត្តសញ្ញាណ និង/ឬ ព័ត៌មានរសើប ដូចបានកំណត់ក្នុងសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយនៃមន្ទីរសន្តិសុខ ដែលរៀបរាប់យ៉ាងលម្អិតអំពីខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានសន្មតថា ទទួលបានដោយការធ្វើទារុណកម្ម។

### ii. "សំណុំឯកសារដែលទទួលបាន"/សេចក្តីថ្លែងសំអាង

55. តាមគោលការណ៍ទូទៅ និងស្របតាមការអនុវត្តពីមុនមក និងត្រង់ចំណុចណាដែលអាចអនុវត្តបាន មាត្រា ៩(ច) នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ[129] សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ឱ្យធ្វើឱ្យសេចក្តីថ្លែងសំអាងទៅជាសាធារណៈ ពេលណាដែលអាចធ្វើទៅបាន ដោយសារធ្វើដូច្នេះ វានឹងអនុញ្ញាតឱ្យមានកំណត់ហេតុពេញលេញមួយអំពីអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុ ព្រមទាំងសេចក្តីសម្រេចនានា នៅក្នុងសំណុំរឿង។ ការណ៍នេះបំរើឱ្យគោលបំណងដ៏សំខាន់នៃតម្លាភាព ការអប់រំ កេរដំណែល និងការកសាងសមត្ថភាព។

---

128 *សូមមើល* **ឧបសម្ព័ន្ធ ក៖** ចម្លើយសារភាពមន្ទីរសន្តិសុខ ប្រវត្តិរូបអ្នកទោស និងសៀវភៅកត់ត្រាដែលបានធ្វើចំណាត់ប្រភេទជាសាធារណៈ។

129 *សូមមើលឧទាហរណ៍* សំណុំរឿង ០០២៖ ឯកសារ **E467/6.3** ការដកចំណាត់ថ្នាក់សំណុំឯកសារដោយ ក.ស.ច.ស។ សំណុំរឿង ០០៣៖ សំណុំរឿង ០០៣-**D274** អនុស្សរណៈ អ.ប.ជ ស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ២។ សំណុំរឿង ០០៣-**D274.1** ឧបសម្ពន្ធ តារាង I (ឯកសារ ក.ស.ព), តារាង II (ឯកសារមេធាវីការពារក្តី មាស មុត), តារាង III (ឯកសារដើមបណ្តឹងរដ្ឋប្បវេណី (០០៣)), តារាង IV (ឯកសារផ្នែកគាំពារការការពារក្តី)។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ការអនុវត្តរបស់ អ.ប.ជ នេះ ត្រូវបានធ្វើឡើងវិញនៅក្នុងសំណុំរឿង ០០៤/១, ០០៤/២ (រួមទាំងឯកសាររបស់ការិយាល័យរដ្ឋបាល) និងសំណុំរឿង ០០៤ (*សូមមើល* សំណុំរឿង ០០៤/១-**D317.1**; សំណុំរឿង ០០៤/២-**D360/47.2**; សំណុំរឿង ០០៤-**D387**)។

56. យ៉ាងណាមិញ កង្វល់អំពីសន្តិសុខនិងឯកជនភាព អាចតម្រូវឱ្យរក្សាទុកនូវសេចក្ដីថ្លែងសំអាងខ្លះជាការសម្ងាត់ និង/ឬ សម្ងាត់បំផុត។ សហព្រះរាជអាជ្ញាយល់ស្របតាម អ.ជ.ត.ក ដែលគួរគប្បីរក្សាទុកជាសម្ងាត់បំផុត ចំពោះ i) សំណើសុំវិធានការការពារនិងឯកសារដែលពាក់ព័ន្ធ, ii) ឯកសារនិងព័ត៌មានដែលស្ថិតក្រោមវិធានការការពារ, iii) ព័ត៌មានពាក់ព័ន្ធនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ និង iv) ឯកសារផ្សេងទៀតដែលមានហេតុផលក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញ[130]។ លើសពីនេះ ដូចបានពិភាក្សាខាងលើ[131] និងបញ្ជាក់បន្ថែមនៅក្នុងសារណារបស់សហមេធាវីនាំមុខ[132] អ.ជ.ត.ក អាចពិចារណាក្នុងការកោសលុបព័ត៌មានរសើបដែលពាក់ព័ន្ធនឹង ឧទាហរណ៍ អំពើហិង្សាផ្លូវភេទ និងយ៉េនឌ័រ ព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកដាក់ពាក្យប្ដឹង សាក្សី ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណី ឬព័ត៌មានដែលបង្ហាញអត្តសញ្ញាណរបស់ចារីដែលបានចោទប្រកាន់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានប្រាប់ឈ្មោះ ហើយព័ត៌មាននោះមិនត្រូវបានធ្វើឱ្យទៅជាសាធារណៈនៅក្នុងដំណាក់កាលជំនុំជម្រះ។

57. សហព្រះរាជអាជ្ញាក៏សន្និដ្ឋានផងដែរថា មានប្រយោជន៍តិចតួចណាស់ក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញលើសំណើសុំកែតម្រូវឯកសារក្នុងសំណុំរឿង ដោយហេតុថា ការកែតម្រូវទាំងនោះក៏ត្រូវបានអនុវត្តរួចរាល់ ហើយច្បាប់ចាស់ ក៏លែងរកបាននៅក្នុងប្រព័ន្ធ Zylab ទៀតដែរ។ លិខិតបញ្ជាក់ស្ដីពីការជំនួសឯកសារ[133] ដែលបានដាក់ក្នុងសំណុំរឿង នៅពេលដែលលេខឯកសារត្រូវបានជំនួស នៅដំណាក់កាលជំនុំជម្រះ ក៏ហាក់ដូចជាមានតម្លៃតិចតួចដែលចាំបាច់សម្រាប់ការធ្វើចំណាត់ប្រភេទឡើងវិញដែរ។ ក៏ប៉ុន្តែ អ.ជ.ត.ក អាចពិចារណាថា តម្លាភាពនៃដំណើរការ មានភាពអនុគ្រោះក្នុងការធ្វើចំណាត់ប្រភេទឡើងវិញចំពោះសំណើទាំងនោះ។

### iii. ឯកសារទាក់ទងនឹងដំណើរការស៊ើបអង្កេត

58. ដំណើរការស៊ើបអង្កេតបានផលិតចេញនូវឯកសារជាច្រើនជំពូកដូចតទៅ៖ ១) លិខិត អនុស្សរណៈ និងឯកសារពាក់ព័ន្ធ ២) ដីកាចាត់ឱ្យស៊ើបសួរជំនួស និងរបាយការណ៍ ៣) ដីកាកោះ ៤) ផែនទី និង ៥) រូបថត។ ឯកសារទាំងនេះបង្ហាញពីជម្រៅ និងទំហំនៃកិច្ចស៊ើបសួរ។ ការធ្វើឱ្យឯកសារស៊ើបអង្កេត

---

[130] ឯកសារ **F71/1/1** សំណើសុំឱ្យដាក់សារណា កថាខណ្ឌ ៤(ខ)។ សេចក្ដីណែនាំអនុវត្តអំពីការធ្វើចំណាត់ប្រភេទឯកសារ កថាខណ្ឌ៦។

[131] *សូមមើល យោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

[132] ឯកសារ **F71** សំណើសុំការណែនាំរបស់ សហមេធាវីនាំមុខ។ *សូមមើលយោងខាងលើ* កថាខណ្ឌ ១៣។

[133] ការស្រាវជ្រាវតាមប្រព័ន្ធ Zylab បង្ហាញថា មានលិខិតបញ្ជាក់ការជំនួសឯកសារស្ទើរតែ ១៩ ០០០ នៅក្នុងសំណុំរឿង ០០២។

ទៅជាសាធារណៈ បើសិនជាអាចធ្វើបាន នឹងជួយលើកកម្ពស់កិត្យានុភាព និងភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ ការផ្តល់នូវទិដ្ឋភាពរួមអំពីការអនុវត្តក្នុងការស៊ើបអង្កេតល្អ ក៏អាចពន្លឿនដល់គុណភាពនៃយុត្តិធម៌ផ្តល់ដោយប្រព័ន្ធច្បាប់ជាតិរបស់កម្ពុជាផងដែរ។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាស្នើឲ្យមានការប្រុងប្រយ័ត្នចំពោះឯកសារទាំងនេះ ដែលមានព័ត៌មានសម្ងាត់ពិស្តារ ទាក់ទងនឹងតម្រុយនៃកិច្ចស៊ើបសួរ ឬសាក្សីសក្តានុពល រួមទាំង ភាគីដើមបណ្តឹងរដ្ឋប្បវេណីផង។ ដោយចងចាំជានិច្ចនូវគោលការណ៍នេះ សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ ដូចតទៅ។

## ក. លិខិត អនុស្សរណៈ និងឯកសារពាក់ព័ន្ធ

59. ឯកសារទាំងនេះអាចបែងចែកជាបីជំពូក។ ជំពូកទី១ គឺជាឯកសារដែលសហព្រះរាជអាជ្ញាយល់ឃើញថាទទួលបានការការពារមិនអាចប្រកែកបាន ហើយដែលត្រូវរក្សាជាការសម្ងាត់។ ជំពូកទី២ គឺជាឯកសារដែលអាចធ្វើឲ្យទៅជាសាធារណៈដោយសុវត្ថិភាព និងជំពូកទី៣ គឺជាឯកសារដែលការធ្វើចំណាត់ប្រភេទរបស់ពួកវានឹងអាស្រ័យលើទម្ងន់ដែល អ.ជ.ត.ក បានផ្តល់ឲ្យ តាមផលប្រយោជន៍ប្រកួតប្រជែង។

60. ឯកសារស្ថិតនៅក្នុងជំពូកទី១ ដែលតាមទស្សនៈរបស់សហព្រះរាជអាជ្ញាគួររក្សាជាការសម្ងាត់នោះ គឺរួមមាន របាយការណ៍របស់អង្គភាព WESU និងការវាយតម្លៃហានិភ័យ (រួមទាំងឯកសារដែលបង្កើតឡើងក្នុងដំណាក់កាលជំនុំជម្រះ និងលើសពីនេះ)[134] លិខិតធានា សំបុត្រកំណើត/មរណភាព អត្តសញ្ញាណប័ណ្ណរបស់អ្នកដាក់ពាក្យបណ្តឹង សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងលិខិតទាក់ទងនឹងសេវាបញ្ជូនឯកសារ (ដែលមានព័ត៌មានលម្អិតអំពីទីតាំងបុគ្គលដែលលិខិតនោះបញ្ជូនទៅ) ។ ចំពោះជំពូកទី២ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារដែលសមស្របសម្រាប់ធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាសាធារណៈ ដោយត្រូវកោសលុបព័ត៌មានរសើប រួមមាន សេចក្តីឆ្លើយឆ្លងរវាង ស.ច.ស និងអង្គជំនុំជម្រះ ក៏ដូចជារវាងអង្គជំនុំជម្រះ អ.វ.ត.ក, ស.ច.ស និង ការិយាល័យរដ្ឋបាល។

61. ចំពោះឯកសារក្នុងជំពូកទី៣វិញ គឺជាឯកសារមានលក្ខណៈជាឯកសាររដ្ឋបាល។ ឯកសារទាំងនោះរួមមាន លិខិតពាក់ព័ន្ធនឹងការធ្វើតំណាងផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ លិខិតប្រគល់សិទ្ធិអំណាច ការដកខ្លួនចេញពីកិច្ចដំណើរការនីតិវិធី ការបញ្ជូនឯកសាររវាងសំណុំរឿង លិខិតរបស់

---

[134] មួយចំនួននៃឯកសារទាំងនេះមាននៅក្នុងគោលការណ៍ណែនាំដែលបានស្នើឡើង ៤(ខ) រួចហើយ - ដែលផ្ទុះបញ្ចាំងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ មាត្រា ៦ - ប៉ុន្តែឯកសារមួយចំនួនមានចំណាត់ប្រភេទជាឯកសារសម្ងាត់។

ក្រឡាបញ្ជី ក.ស.ច.ស ទាក់ទងនឹងឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរឋានៈ (ការផ្លាស់ប្តូរពីអ្នកប្តឹងទៅជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)។ អាចថាមានតម្លៃខ្លះៗក្នុងការអនុញ្ញាតឱ្យឯកសាររដ្ឋបាលដូច្នេះបានទៅដល់សាធារណជន ដើម្បីជាផលប្រយោជន៍តម្លាភាព និងការកសាងសមត្ថភាព។ យ៉ាងណាមិញ សំខាន់គួរកត់សម្គាល់ថា មានឯកសារខ្លះមានផ្ទុកនូវព័ត៌មានទំនាក់ទំនងលម្អិត និងលេខអត្តសញ្ញាណប័ណ្ណបុគ្គល និងលេខទាក់ទងដែលទាមទារឱ្យមានការកោសលុប។ លើសពីនេះទៀត បើសិនជាលិខិតណាមួយពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ការធ្វើចំណាត់ថ្នាក់ឡើងវិញគឺអាចធ្វើបានវៀរលែងតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ ទំនងជាត្រូវបានទទួលយកដោយ ស.ច.ស រួចហើយនិងជាថ្មីម្តងទៀត ឯកសារទាំងនេះ គឺជាកម្មវត្ថុនៃការកោសលុបមុនពេលធ្វើឱ្យទៅជាសាធារណៈ[135]។ សហព្រះរាជអាជ្ញាផ្តល់សញ្ញាដល់ អ.ជ.ត.ក ដើម្បីពិចារណាលើបញ្ហាទាំងអស់នេះនិងដើម្បីការអនុវត្តស្របគ្នា និងកត់សម្គាល់ថា អនុលោមតាមវិធាន ៧.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទព័ត៌មានទំនាក់ទំនងរបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានកោសលុបចេញពីឯកសារទាំងអស់ និងមិនត្រូវដាក់ជាសាធារណៈទេ ដូចដែលគោលការណ៍ណែនាំដែលបានស្នើឡើង ៤(ក)(iv) បានប្រមើល។

## ខ. ដីកាចាត់ឱ្យស៊ើបសួរជំនួស និងរបាយការណ៍

62. ដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលចាត់តាំងការងារស៊ើបសួរជាក់លាក់ដល់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងរបាយការណ៍ស្តីពីការអនុវត្តដីកាទាំងនោះ[136] តែងតែមានផ្ទុកនូវព័ត៌មានដែលនៅតែត្រូវរក្សាការពារ។ ដោយមានការថ្លឹងថ្លែងអំពីគោលការណ៍ទូទៅនៃការរក្សាការសម្ងាត់ចំពោះឯកសារស៊ើបអង្កេតដូច្នេះ ធៀបនឹងអត្ថប្រយោជន៍នៃតម្លាភាព សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងនេះ ទៅជាសាធារណៈ ប៉ុន្តែដោយមានការប្រុងប្រយ័ត្នខ្លាំងចំពោះការកោសលុបនូវព័ត៌មានកំណត់អត្តសញ្ញាណ និងព័ត៌មានរសើប។

## គ. ដីកាកោះ

63. ភាគច្រើននៃដីកាកោះមុនការជំនុំជម្រះ គឺជាដីកាកោះដែលបានបញ្ជូនទៅសាក្សីឱ្យចូលខ្លួនមកផ្តល់ចម្លើយជាមួយ ក.ស.ច.ស (ដីកាកោះផ្សេងទៀតក្រោយមកត្រូវបានបញ្ជូនដោយ អ.ជ.ស.ដ និង

---

[135] *សូមមើល យោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

[136] ព័ត៌មានទាំងនេះជាញឹកញាប់កំណត់អត្តសញ្ញាណអ្នកដែលមិនយល់ព្រមផ្តល់ចម្លើយផ្លូវការ ប៉ុន្តែបាននិយាយជាចំហ ដោយរំពឹងថាតួនាទីរបស់ពួកគេក្នុងការផ្តល់តម្រុយស៊ើបអង្កេតនឹងនៅតែត្រូវបានរក្សាការសម្ងាត់។

អ.ជ.ត.ក ដែលត្រូវនៅតែរក្សាការសម្ងាត់ដដែល)។ ទោះបីជាមានបុគ្គលខ្លះក្នុងចំណោមអ្នកទាំងនេះ ក្រោយមកបានចូលមកផ្តល់សក្ខីកម្មនៅពេលសវនាការក៏ដោយ ក៏ឯកសារទាំងនេះកំណត់អត្តសញ្ញាណបុគ្គលម្នាក់ៗដែលមានការរំពឹងទុកអំពីឯកជនភាព ពេលពួកគេសហការណ៍នៅក្នុងកិច្ចស៊ើបសួរ។ ឯកសារទាំងនេះក៏មានព័ត៌មានទំនាក់ទំនងលម្អិតដែលត្រូវរក្សាជាឯកជន។ ហេតុដូចនេះ សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ឱ្យរក្សាឯកសារដូច្នេះជាការសម្ងាត់ដដែល ដោយសារតែសិទ្ធិឯកជនរបស់បុគ្គលម្នាក់ៗ មានទម្ងន់ធ្ងន់ជាងផលប្រយោជន៍ក្នុងការធ្វើឱ្យឯកសារដូច្នេះទៅជាសាធារណៈ។ បើសិនជាមានការសម្រេចដើម្បីធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងនេះ នោះនឹងតម្រូវឱ្យមានការកោសលុបជាច្រើន។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញា*ពិតជា* ផ្តល់អនុសាសន៍ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅជាសាធារណៈចំពោះដីកាកោះ ដែលកោះហៅជនជាប់ចោទ និង/ឬមេធាវីរបស់ពួកគេក្នុងសំណុំរឿង ០០២ ឱ្យចូលបង្ហាញខ្លួនលើកដំបូង និងការបង្ហាញខ្លួនបន្ថែមទៀត នៅចំពោះមុខ ស.ច.ស និង អ.ប.ជ រួមទាំងនៅក្នុងសវនាការអំពីការឃុំខ្លួនបណ្តោះអាសន្ន (ក៏ដូចជាឱ្យចូលរួមក្នុងសវនាការនៅចំពោះមុខ អ.ជ.ស.ដ និង អ.ជ.ត.ក) ក៏ដូចជាដីកាបង្គាប់ឱ្យនាំខ្លួនរបស់ពួកគេ។

## ឃ. ផែនទី

64. ឯកសារទាំងនេះ រួមមាន គំនូសព្រាងទីតាំងឧក្រិដ្ឋកម្មដែលបានគូសដោយសាក្សី និងផែនទីជាតិ និងតំបន់ ដែលមានកាលបរិច្ឆេទក្រោយរបប និងជាឯកសារជំនួយសម្រាប់ឱ្យយើងដឹងអំពីទីតាំងដែលបាននិយាយក្នុងភស្តុតាងជាសក្ខីកម្ម និងភស្តុតាងជាឯកសារ។ តាមគោលការណ៍ទូទៅ សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើផែនទីទាំងនេះទៅជាសាធារណៈ។

## ង. រូបថត

65. រូបថតនៅក្នុងសំណុំរឿង ០០២ រួមមាន រូបថតទីតាំងឧក្រិដ្ឋកម្ម សៀវភៅដាក់រូបថត រូបថតដែលបានបង្ហាញសាក្សីសក្តានុពលដែលអ្នកស៊ើបអង្កេត ក.ស.ច.ស បានសួរឱ្យកំណត់អត្តសញ្ញាណមនុស្សនៅក្នុងរូបថតនោះ (រូបថតបែបនេះ បន្ទាប់មកត្រូវបានដាក់ភ្ជាប់ទៅនឹងចម្លើយ) រូបថតដើមបណ្តឹងរដ្ឋប្បវេណីសក្តានុពល និងរូបថតពីឯកសារអត្តសញ្ញាណកម្ម។ តាមគោលការណ៍ទូទៅ សហព្រះរាជ

អាជ្ញាសូមផ្តល់អនុសាសន៍ឱ្យដាក់រូបថតទាំងនេះ ទៅជាសាធារណៈ លើកលែងតែមានការកង្វល់អំពីឯកជនភាពដែលតម្រូវឱ្យធ្វើផ្សេងពីនេះ[137]។

### iv. ការស្រាវជ្រាវ និងប្រភពឯកសារយោង

66. សំណុំរឿង ០០២ មាន (១) អត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់ (២) សៀវភៅ (៣) របាយការណ៍វិភាគ (៤) អត្ថបទសារព័ត៌មាន ដែលចុះកាលបរិច្ឆេទក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ និង (៥) ឯកសារជាខ្សែវីដេអូ ទាក់ទងនឹងខ្មែរក្រហម (ក្នុងករណីខ្លះ ក៏មានប្រតិចារឹកផងដែរ) និង ច្បាប់ជាតិ និងអន្តរជាតិ យុត្តិសាស្ត្រ និងសេចក្តីអត្ថាធិប្បាយ។ ជាចំបង ឯកសារទាំងនេះ គឺជាកិច្ចការរបស់អ្នកសិក្សាជាន់ខ្ពស់ អ្នកសារព័ត៌មាន និងអ្នកផលិតភាពយន្ត ដែលជួយពន្យល់អំពីទិដ្ឋភាពសំខាន់ៗនៃរបបកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់របបនេះ ក៏ដូចជាឯកសារសំអាងផ្លូវច្បាប់ដែលផ្អែកលើដោយភាគី និងចៅក្រម។ ការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងនេះ នឹងជួយពន្លឿនចំពោះគោលបំណងស្តីពីតម្លាភាព ការអប់រំ ការកសាងសមត្ថភាព និងកេរដំណែលរបស់តុលាការ។ សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ថា ជាទូទៅ ត្រូវដាក់កំណត់ហេតុទាំងនេះទៅជាសាធារណៈ។

### *មាត្រា ៥.១(គ): កំណត់ហេតុស្តាប់ចម្លើយ ប្រតិចារឹក និងខ្សែអាត់សំឡេង/វីដេអូនៃការស្តាប់ចម្លើយ និងកិច្ចស៊ើបសួរផ្សេងៗទៀត ដែលបានធ្វើឡើងដោយ ស.ច.ស ឬអ្នកដែលបានទទួលសិទ្ធិប្រតិភូកម្មអំណាច*

67. បន្ថែមលើចំណុចដែលបានពិភាក្សាខាងលើ ឯកសារដែលស្ថិតក្នុងមាត្រា ៥.១(គ) (ក៏ដូចជា ៥.១(ខ), (ឃ), (ង) និង (ឆ)) នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ គឺស្ថិតក្នុងជំពូកធំៗចំនួនពីរ៖ i) ភស្តុតាងជាចម្លើយ និងជាសក្ខីកម្ម និង ii) របាយការណ៍ ដែលសហព្រះរាជអាជ្ញាលើកឡើងតាមលំដាប់លំដោយ។

### i. ចម្លើយ និងភស្តុតាងសក្ខីកម្ម

68. សំណុំរឿង ០០២ មានកំណត់ហេតុសួរចម្លើយជនសង្ស័យ កំណត់ហេតុស្តាប់ចម្លើយ (របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ) ដោយមានប្រតិចារឹកនិងខ្សែអាត់សំឡេង/វីដេអូដែលពាក់ព័ន្ធ បទសម្ភាសន៍ DC-Cam ពាក្យបណ្តឹង VIS និង SIF ហើយនឹងរបាយការណ៍ VSS ដែលពាក់ព័ន្ធ។ សម្ភារទាំងនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយស្វែងរកការពិតអំពីឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយហេតុថា វានឹងផ្តល់នូវរឿងរ៉ាវដំបូង

---

[137] *សូមមើលឧទាហរណ៍* ឯកសារ **F71** សំណើរបស់ សហមេធាវីនាំមុខសុំការសម្រេច កថាខណ្ឌ ៣៨។

អំពីព្រឹត្តិការណ៍ផ្សេងៗ ហើយក៏មានសារសំខាន់ទាំងសម្រាប់គោលបំណងជាភ័ស្តុតាង និងជាប្រវត្តិសាស្ត្រ។ ដោយមានករណីលើកលែងខ្លះដូចបានកត់សម្គាល់ខាងក្រោម សហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ថា ជាទូទៅ សម្ភារទាំងនេះត្រូវធ្វើឲ្យទៅជាសាធារណៈ ប៉ុន្តែអាចធ្វើដូច្នេះបាន លុះត្រាតែមានការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន ហើយព័ត៌មានឯកជន និងព័ត៌មានរសើប ត្រូវបានកោសលុបតែប៉ុណ្ណោះ[138]។ ការធានាឲ្យប្រាកដថាសម្ភារទាំងនេះត្រូវបានធ្វើទៅជាសាធារណៈតាមដែលអាចធ្វើបាន នឹងអនុញ្ញាតឲ្យមនុស្សជំនាន់ក្រោយ និងអ្នកស្រាវជ្រាវបានយល់ដឹងកាន់តែប្រសើរ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍នានា ព្រមទាំង បទចោទនៅក្នុងសំណុំរឿងទាំងនេះ ខណៈដែលការកោសលុបនឹងការពារសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលម្នាក់ៗដែលបានចូលរួមនៅក្នុងដំណើរការរបស់ អ.វ.ត.ក។

## ក. កំណត់ហេតុសួរចម្លើយជនសង្ស័យ

69. ប្រភេទកំណត់ហេតុនេះ គឺជាកំណត់ហេតុដែលបានធ្វើឡើងដោយ អៀង សារី, នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ, កាំង ហ្កេកអ៊ាវ ហៅ ឌុច ក៏ដូចជា មាស មុត, អោ អាន និង អ៊ឹម ចែម។ មានកំណត់ហេតុខ្លះត្រូវបានធ្វើឡើងក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្លះបានធ្វើឡើងនៅក្រោយពេលដែលរបបនេះដួលរលំ ប៉ុន្តែនៅតែមុនពេលដែលអ្នកថ្លែងក្នុងកំណត់ហេតុបានក្លាយជាជនសង្ស័យរបស់ អ.វ.ត.ក (ដូចជាទៅកាន់ DC-Cam) និងមានខ្លះទៀតត្រូវបានធ្វើឡើងបន្ទាប់ពីអ្នកថ្លែងក្នុងកំណត់ហេតុបានដឹងខ្លួនថា ខ្លួនគឺជាជនសង្ស័យ ឬជនត្រូវចោទរបស់ អ.វ.ត.ក។ ដោយសារតែកំណត់ហេតុទាំងនេះ ត្រូវបានធ្វើឡើងដោយអតីតមេដឹកនាំ ឯកសារទាំងនេះផ្តល់នូវទិដ្ឋភាពដ៏សំខាន់ និងតែមួយគត់អំពីព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើង ហើយសហព្រះរាជអាជ្ញាសូមផ្តល់អនុសាសន៍ឲ្យដាក់ឯកសារទាំងនេះទៅជាសាធារណៈ។

## ខ. សម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី រួមទាំងប្រតិចារឹក និងខ្សែអាត់សំឡេង/វីដេអូ

70. ជាការបន្ថែមទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់ឲ្យ ក.ស.ច.ស និង DC-Cam ជាមួយនឹងប្រតិចារឹកនៃកំណត់ហេតុទាំងនោះ ហើយនឹងខ្សែអាត់សំឡេង/វីដេអូនៃការស្តាប់ចម្លើយដែលពាក់ព័ន្ធនឹងបទសម្ភាសន៍របស់ ក.ស.ច.ស គឺថាសម្ភារទាំងនេះ រួមមានប្រតិចារឹកសវនាការសំណុំរឿង ០០១ ការសិក្សាស្ទង់មតិអំពីអំពើហិង្សាផ្លូវភេទ កំណត់ហេតុអំពី

[138] *សូមមើលយោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

ការលះបង់សិទ្ធិមានវត្តមានមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស ព្រមទាំងកំណត់ហេតុធ្វើសម្បថរបស់អ្នកបកប្រែផ្ទាល់មាត់ អ្នកបកប្រែឯកសារ និងសាក្សី។

71. ដោយត្រូវកោសលុបនូវព័ត៌មានទំនាក់ទំនងពិស្តារ និងព័ត៌មានរសើបផ្សេងទៀត[139] ក៏ដូចជាការពិគ្រោះយោបល់សមស្របជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាយល់ឃើញថា ដើម្បីផលប្រយោជន៍នៃការអប់រំ កេរដំណែល និងការកសាងសមត្ថភាព កំណត់ហេតុស្តាប់ចម្លើយ កំណត់ហេតុ DC-Cam និងប្រតិចារឹកនៃកំណត់ហេតុស្តាប់ចម្លើយ ប្រតិចារឹកសវនាការសំណុំរឿង ០០១ សម្ភារដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងដែលបានកត់សម្គាល់ផ្សេងទៀត គួរតែធ្វើឱ្យទៅជាសាធារណៈ។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមថា កំណត់ហេតុនៃការលះបង់សិទ្ធិមានវត្តមានមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ហេតុធ្វើសម្បថរបស់បុគ្គលផ្សេងៗ គឺមានចរិកលក្ខណៈជាឯកសាររដ្ឋបាល និងមិនមែនជាមូលដ្ឋានសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញឡើយ។ បើសិនអង្គជំនុំជម្រះមិនយល់ស្រប សហព្រះរាជអាជ្ញាសូមកត់សម្គាល់ថា ឯកសារទាំងនេះភាគច្រើន គឺមានព័ត៌មានទំនាក់ទំនងផ្ទាល់ខ្លួនដែលគួរត្រូវបានកោសលុប។ លើសពីនេះ បើសិនជាមានសម្ភារណាមួយពាក់ព័ន្ធនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី សម្ភារនោះអាចនឹងធ្វើចំណាត់ថ្នាក់ឡើងវិញទៅបាន លុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធ ទំនងជាត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២។

72. ពាក់ព័ន្ធនឹងគោលការណ៍ណែនាំដែលបានស្នើឡើង ៥(ក)(v)[140] អំពីការធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះឯកសារទាក់ទងនឹងសវនាការដែលបានធ្វើឡើង*ជាសម្ងាត់* សហព្រះរាជអាជ្ញាគាំទ្រការរកឃើញរបស់ អ.ប.ជ ដែលថា ការពិតដែលសវនាការត្រូវបានធ្វើឡើងជាសម្ងាត់ មិនមែនជាលទ្ធផលធ្វើឱ្យប្រតិចារឹក និងខ្សែអាត់សំឡេង/វីដេអូ នៅតែជាកំណត់ហេតុអសាធារណៈជាស្វ័យប្រវត្តិនោះទេ[141]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អនុលោមតាមវិធានការការពារដែលនៅជាធរមាន សម្ភារទាំងនេះត្រូវធ្វើឱ្យទៅជាសាធារណៈ ដោយមានការកោសលុបព័ត៌មានរសើប[142]។

---

[139] *សូមមើលយោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

[140] ដែលឆ្លុះបញ្ចាំងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ មាត្រា ៥.១(ផ)។

[141] *សូមមើល* សំណុំរឿង០០៤/១-**D304/6/4** សេចក្តីសម្រេចរបស់ អ.ប.ជ លើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ២៩។

[142] *សូមមើលយោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

## ii. របាយការណ៍

73. សំណុំរឿង ០០២ ដាក់បញ្ចូល*ជាអាទិ៍*បាយការណ៍ស៊ើបអង្កេតតាមតំបន់របស់ DC-Cam របាយការណ៍កំណត់អត្តសញ្ញាណទីតាំងរបស់ ក.ស.ច.ស សហព្រះរាជអាជ្ញាយល់ឃើញថា ចំពោះរបាយការណ៍ស៊ើបអង្កេតតាមតំបន់របស់ DC-Cam គឺយើងអាចធ្វើឱ្យវាទៅជាសាធារណៈបានដោយសុវត្ថិភាព។ ដើម្បីលើកកម្ពស់តម្លាភាព និងការអប់រំ របាយការណ៍កំណត់អត្តសញ្ញាណទីតាំង គឺយើងគួរតែធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ ប៉ុន្តែការធ្វើដូច្នេះបាន ទាល់តែយើងបានធ្វើការកំណត់ជាមុនសិន ថាតើ យើងត្រូវការកោសលុបព័ត៌មានណាមួយតាមការចាំបាច់ឬទេ ដើម្បីការពារព័ត៌មានរសើប រួមមានអត្តសញ្ញាណប្រភពផ្តល់តម្រុយនៅក្នុងកិច្ចស៊ើបសួរ ប៉ុន្តែគាត់មិនយល់ព្រមផ្តល់ចម្លើយជាផ្លូវការ។

### *មាត្រា ៥.១(ច)៖ សេចក្តីសម្រេច ដីកា និងការរកឃើញផ្សេងៗទៀតរបស់សហចៅក្រមស៊ើបអង្កេត*

74. ដូចបានប្រមើលដោយគោលការណ៍ណែនាំដែលបានស្នើឡើង[143] និងបានផ្តល់អនុសាសន៍ដោយ អ.ប.ជ[144] សហព្រះរាជអាជ្ញាឯកភាពថា សេចក្តីសម្រេច ដីកា/ដីកាសម្រេច និងការរកឃើញផ្សេងទៀតដោយ ស.ច.ស គួរតែធ្វើឱ្យទៅជាសាធារណៈ ដោយស្ថិតក្រោមវិធានការការពារជាធរមាន ហើយព័ត៌មានរសើបផ្សេងទៀតក៏គួរតែកោសលុបផងដែរ[145]។ អាស្រ័យដោយមូលហេតុដូចគ្នា និងស្ថិតក្រោមលក្ខខណ្ឌដូចគ្នា ដីកាបង្គាប់ និងសេចក្តីសម្រេចរបស់ អ.ប.ជ ក៏គួរតែធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈផងដែរ[146]។

## សម្ភារដែលត្រូវរក្សាសិទ្ធិអ្នកនិពន្ធ

75. ពាក់ព័ន្ធនឹងគោលការណ៍ណែនាំដែលបានស្នើឡើង ៤(ង) សហព្រះរាជអាជ្ញាកត់សម្គាល់ថា ឃ្លាថា “ការផ្សព្វផ្សាយជាសាធារណៈ” និង “ទទួលបានការការពារតាមច្បាប់សិទ្ធិអ្នកនិពន្ធជាធរមាន” ដោយឃ្លាទាំងពីរ សុទ្ធតែមិនច្បាស់លាស់ដូចគ្នា។ ដូចបានពិភាក្សាខាងលើ អ.វ.ត.ក គួរលើកទឹកចិត្តជាទូទៅ

---

[143] **F71/1/1** សំណើសុំឱ្យដាក់សារណា កថាខណ្ឌ ៤(ខ)(vi), ៤(គ)។

[144] *សូមមើល* ឯកសារ **F67** អនុស្សរណៈ អ.ប.ជ ខែឧសភា ឆ្នាំ២០២១ ស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញ។ ឯកសារ **F71/1/1/1** អនុស្សរណៈ អ.ប.ជ ខែសីហា ឆ្នាំ២០២២ ស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញ។

[145] *សូមមើលយោងខាងលើ* កថាខណ្ឌ ៣, ១៣, ២៥-២៧។

[146] វិធាន ៧៨ នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ជើងទំព័រ ១៤៤ *យោងខាងលើ*។

ឲ្យមានការសិក្សាស្រាវជ្រាវ រៀនសូត្រ និងអប់រំ អំពីសម័យកាលខ្មែរក្រហម។ ការណ៍នេះរួមបញ្ចូលទាំងការបង្កលទ្ធភាព និងពង្រីកវិសាលភាព ដើម្បីឲ្យឯកសារសាធារណៈទាំងអស់នៅ អ.វ.ត.ក បានដល់សាធារណជន។ បច្ចុប្បន្ន មិនទាន់មានបទដ្ឋានគ្រប់គ្រងអន្តរជាតិដែលអាចបញ្ជាក់បានថាតើ ការធ្វើឲ្យព័ត៌មានដែលអាចទទួលបានជាសាធារណៈ តាមរយៈវិបសាយរបស់តុលាការកូនកាត់ ឬតុលាការអន្តរជាតិណាមួយ[147] គឺជា "ការផ្សព្វផ្សាយជាសាធារណៈ" នៅឡើយទេ។

76. ដោយពិចារណាអំពីលក្ខខណ្ឌតម្រូវក្នុងកិច្ចព្រមព្រៀងបន្ថែម ក្នុងការធ្វើឲ្យបណ្ណសារ អ.វ.ត.ក "អាចចូលមើលបានយ៉ាងទូលំទូលាយ" រួមទាំងដោយការផ្តល់ការចូលមើលសំណៅអេឡិចត្រូនិកចំពោះបណ្ណសារសាធារណៈ[148] អ.ជ.ត.ក អាចមានបំណងពិចារណាទៅលើ តុល្យភាពនៃការប្រើប្រាស់ ដូចបានកំណត់ដោយតុលាការកំពូលកាណាដា នៅក្នុងរឿងក្តី *CCH Canada Ltd ទល់នឹង Law Society of Upper Canada* ("Law Society")[149]។ ក្នុងរឿងក្តីនេះ គឺពាក់ព័ន្ធនឹងសេវាកម្មបោះពុម្ព ដែលផ្តល់ដោយ Law Society នៅរោងពុម្ព Great Library ដែលមានសម្ភារៈកម្មសម្ភារច្បាប់ជាច្រើន។ តាមការស្នើសុំរបស់អ្នកប្រើប្រាស់ បុគ្គលិករោងពុម្ព Great Library នេះផ្ទាល់ គឺជាអ្នកដែលបានថតចម្លងនូវសម្ភារដែលទទួលបានការការពារ ហើយ Law Society បានអះអាងថា នេះគឺជាការធ្វើជំនួញយុត្តិធម៌ ពីព្រោះវាធ្វើឡើងសម្រាប់ការស្រាវជ្រាវ ស្របតាមពាក្យពេចន៍នៃបញ្ញត្តិច្បាប់ជាធរមាន។ តុលាការកំពូលកាណាដា បានថ្លែងថា "ដើម្បីរក្សាបាននូវតុល្យភាពត្រឹមត្រូវរវាងសិទ្ធិអ្នកនិពន្ធរបស់ម្ចាស់កម្មសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់ [ជាករណីលើកលែងចំពោះការធ្វើជំនួញយុត្តិធម៌] មិនត្រូវបកស្រាយក្នុងន័យរឹតត្បិតឡើយ"[150] និងថា "'ការស្រាវជ្រាវ' ត្រូវតែផ្តល់ឲ្យមានការបកស្រាយធំទូលាយ និងដោយសេរី ដើម្បីធានាឲ្យប្រាកដថា សិទ្ធិរបស់អ្នកប្រើប្រាស់ មិនត្រូវបានកំហិតដោយមិនត្រឹមត្រូវ"[151]។ ចំពោះអត្ថន័យនៃពាក្យថា "យុត្តិធម៌" តុលាការ

---

[147] សហព្រះរាជអាជ្ញាកត់សម្គាល់ថា គោលការណ៍ដែលបានស្នើឡើង ៤(ង) - ផ្ទះបញ្ចាំងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ មាត្រា ១២.៣ - វាមិនមែនជាសំណួរនៃការធ្វើចំណាត់ប្រភេទទេ ប៉ុន្តែជាការចូលមើល។ ជាពិសេសវាអាចអនុវត្តបានចំពោះសំណួរថាតើត្រូវផ្ទុកឯកសារដែលត្រូវបានចាត់ថ្នាក់ជាសាធារណៈទៅកាន់គេហទំព័ររបស់ អ.វ.ត.ក ឬទេ។ *សូមមើលបន្ថែមទៀត* ឯកសារ **E319/35/15/2** អនុស្សរណៈ ស.ច.ស.អ ស្តីពីការធ្វើចាត់ប្រភេទឡើងវិញ កថាខណ្ឌ ៩។

[148] កិច្ចព្រមព្រៀងបន្ថែម មាត្រា ៣(១), (២)។

[149] *CCH Canadian Ltd. ទល់នឹង Law Society of Upper Canada*, 2004 SCC 13 ("CCH *ទល់នឹង* Law Society")។

[150] CCH *ទល់នឹង* Law Society, កថាខណ្ឌ ៤៨។

[151] CCH *ទល់នឹង* Law Society, កថាខណ្ឌ ៥៨។

បានយោងសំដៅសាលក្រមរបស់ Lord Denning នៅក្នុងរឿងក្តី *Hubbard ទល់នឹង Vosper*,[152] ដែលថ្លែងយ៉ាងដូច្នេះថា៖

> គេមិនអាចកំណត់និយមន័យនៃឃ្លា "ការធ្វើជំនួញយុត្តិធម៌" បានទេ។ វាគឺជាចំណោទ ស្តីពីកម្រិត។ អ្នកត្រូវពិចារណាជាចំបងទៅលើចំនួន និងវិសាលភាពនៃសម្រង់ និងការចម្លង។ តើសម្រង់ និងការចម្លងទាំងនោះ ច្រើនពេក និងវែងពេក មិនយុត្តិធម៌? បន្ទាប់មក យើងត្រូវពិចារណាលើការប្រើប្រាស់សម្រង់ និងការចម្លងទាំងនោះ។ បើសិនជាគេប្រើវាជាមូលដ្ឋានសម្រាប់ការផ្តល់យោបល់ ការរិះគន់ ឬការពិនិត្យឡើងវិញ នោះអាចជាការធ្វើជំនួញយុត្តិធម៌។ បើសិនជាគេប្រើវាដើម្បីផ្ទេរព័ត៌មានដដែល ដូចអ្នកនិពន្ធ ក្នុងគោលបំណងជាគូប្រជែង នោះអាចថា មិនយុត្តិធម៌។ បន្ទាប់មកទៀត អ្នកត្រូវពិចារណាអំពីសមាមាត្រ។ ការយកចម្លងវែង ទៅភ្ជាប់នឹងយោបល់ខ្លី អាចមិនយុត្តិធម៌ទេ។ ប៉ុន្តែ ក្រោយពីបានបញ្ជាក់អ្វីៗគ្រប់យ៉ាងមក ឃើញថាវាគឺជាបញ្ហានៃការបញ្ជាក់អត្ថន័យ គឺដូចគ្នានឹងឃ្លាថា យោបល់យុត្តិធម៌ នៅក្នុងច្បាប់បរិហារកេរ្តិ៍ និងឃ្លាថា ការធ្វើជំនួញយុត្តិធម៌ នៅក្នុងច្បាប់សិទ្ធិអ្នកនិពន្ធ ដែរ។ តុលាការដែលកាត់ក្តីលើអង្គហេតុ ត្រូវសម្រេចលើបញ្ហានេះ[153]។

77. តុលាការកំពូលកាណាដា បានពិចារណាលើគោលនយោបាយបង្កលទ្ធភាពរបស់បណ្ណាល័យ និងកត្តាមួយចំនួនដែលបានលើកឡើងដោយ Linden JA នៅតុលាការឧទ្ធរណ៍ មានដូចជា ១) គោលបំណងនៃការធ្វើជំនួញ ២) ប្រភេទនៃការធ្វើជំនួញ ៣) បរិមាណនៃការធ្វើជំនួញ ៤) ជម្រើសនៃការធ្វើជំនួញ ៥) ប្រភេទនៃការងារជាចំណោទ និង ៦) ប្រសិទ្ធភាពនៃការធ្វើជំនួញលើការងារនោះ ហើយបានកំណត់ថា កត្តាទាំងនេះផ្តល់នូវក្របខ័ណ្ឌការងារវិភាគដ៏មានប្រយោជន៍ ក្នុងការគ្រប់គ្រងទៅលើការកំណត់អំពីភាពយុត្តិធម៌នៅក្នុងករណីនានាក្នុងពេលអនាគត[154]។

78. ដោយសារតែតម្លៃខ្ពស់ជាពិសេសនៃសម្ភាររបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ.ជ.ត.ក គួរតែពិចារណាដោយប្រុងប្រយ័ត្នដោយមិនត្រូវកំហិតដោយមិនត្រឹមត្រូវ ចំពោះការផ្តល់លទ្ធភាពដល់សមាជិកនៃសាធារណជនដែលមានបំណងចង់ប្រើប្រាស់ដោយយុត្តិធម៌ សម្រាប់គោលបំណងនៃការ

---

[152] *Hubbard ទល់នឹង Vosper* [1972] 1 All E.R. 1023 (C.A.)។

[153] CCH *ទល់នឹង* Law Society, កថាខណ្ឌ ៥២ *យោង Hubbard ទល់នឹង Vosper*, ទំព័រ ១០២៧ ([1972] 2 Q.B. 84, ត្រង់ ៩៤)។

[154] CCH *ទល់នឹង* Law Society, កថាខណ្ឌ ៥៣។

អប់រំនិងស្រាវជ្រាវ នូវសម្ភារដែលស្ថិតក្រោមការកាន់កាប់របស់ អ.វ.ត.ក ក្នុងរបៀបមួយដែលមានការទទួលស្គាល់ដោយច្បាប់សិទ្ធិអ្នកនិពន្ធរបស់បណ្តារដ្ឋជាច្រើន ខណៈក្នុងពេលជាមួយគ្នាក៏មានការថែរក្សាសិទ្ធិរបស់ម្ចាស់សិទ្ធិអ្នកនិពន្ធ។ ដើម្បីឲ្យមានការប្រើប្រាស់ដោយការថ្លឹងថ្លែងត្រឹមត្រូវ អ.ជ.ត.ក អាចមានបំណងដាក់លក្ខខណ្ឌតម្រូវឲ្យអ្នកប្រើប្រាស់ ដែលស្វែងរកលទ្ធភាពចូលពិនិត្យកំណត់ហេតុណាមួយស្ថិតក្រោមការកាន់កាប់របស់ អ.វ.ត.ក ទទួលយកលក្ខខណ្ឌជាក់លាក់ដូចមានចែងនៅក្នុងគោលនយោបាយស្តីពីលទ្ធភាពចូលមើលឯកសារ ក្នុងរបៀបស្រដៀងទៅនឹងអភិក្រមដែលបានអនុម័តនៅ IRMCT លើវិបសាយរបស់ពួកគេ[155]។ លក្ខខណ្ឌដែលអាចដាក់បញ្ចូល មានដូចជា លក្ខខណ្ឌតម្រូវឲ្យអ្នកប្រើប្រាស់ទទួលយក ១. ការអនុញ្ញាតបង្កលទ្ធភាពចូលមើលឯកសារ ផ្តល់ដោយ អ.វ.ត.ក មិនត្រូវបកស្រាយថា ជាការជម្រះ/ធ្វើឲ្យជ្រះស្រឡះពីសិទ្ធិអ្នកនិពន្ធឡើយ ២. អ្នកប្រើប្រាស់អាចប្រើប្រាស់សម្ភារដោយយុត្តិធម៌ ក្នុងគោលបំណងនៃការស្រាវជ្រាវ ការសិក្សា ឬការអប់រំដែលមិនមែនលក្ខណៈពាណិជ្ជកម្ម ស្របតាមច្បាប់សិទ្ធិអ្នកនិពន្ធជាធរមាន ក្នុងឆន្ទានុសិទ្ធិរបស់អ្នកប្រើប្រាស់ និង ៣. ប្រសិនបើអ្នកប្រើប្រាស់មានបំណងប្រើប្រាស់សម្ភារក្នុងរបៀបណាមួយផ្សេងទៀត រួមទាំងការផ្សព្វផ្សាយសម្ភារផង នោះអ្នកប្រើប្រាស់ត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកនិពន្ធ។

### គ. ការដកចំណាត់ប្រភេទឯកសារក្នុងពេលអនាគត

79. សហព្រះរាជអាជ្ញាកត់សម្គាល់ថា ការប្រើប្រាស់ដោយតុល្យភាពរវាងសិទ្ធិសាធារណជន ក្នុងការទទួលបានលទ្ធភាពចូលមើលកំណត់ហេតុបង្កើតឡើងដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ (រួមទាំង ចម្លើយសារភាពដែលប្រមូលបានក្រោមលទ្ធផលនៃការធ្វើទារុណកម្ម) និងសិទ្ធិឯកជន មានការផ្លាស់ប្តូរជាហូរហែមក។ កាលណាពេលវេលាកាន់តែច្រើនកាន់តែកន្លងផុតទៅ សិទ្ធិរបស់សាធារណជនក្នុងការចូលពិនិត្យសម្ភារទាំងនេះ ក៏កាន់តែច្រើន។ ហេតុដូចនេះ អ.ជ.ត.ក អាចមានបំណងផ្តល់លទ្ធភាពកាន់តែច្រើនក្នុងការចូលពិនិត្យកំណត់ហេតុនាពេលអនាគត ដូចជាចម្លើយសារភាពនិងប្រវត្តិរូបដែលទទួលបានពីអ្នកទោសតាមមន្ទីរសន្តិសុខនានារបស់កម្ពុជាប្រជាធិបតេយ្យ។ ស្របតាមស្មារតីនៃគោលការណ៍ណែនាំរបស់អគ្គលេខាធិការ អ.ស.ប ស្តីពីការធ្វើចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានរសើប នៅតាមបណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិនានា[156] អ.ជ.ត.ក អាចពិចារណាផ្តល់ឲ្យអាជ្ញាធរដែលស្នងតំណែងបន្តនៅ អ.វ.ត.ក នូវសិទ្ធិដកចំណាត់ប្រភេទឯកសារដោយស្វ័យប្រវត្តិ ចំពោះសម្ភារ

---

[155] IRMCT គោលការចូលមើល មាត្រា ១១(៨)។ គេហទំព័រ IRMCT លក្ខខណ្ឌនៃការប្រើប្រាស់ មាត្រា (គ), (ឃ), (ង)។

[156] ព្រឹត្តិបត្រអំពីភាពរសើបនៃព័ត៌មាន ICT ឆ្នាំ២០១២ របស់អគ្គលេខាធិការ ផ្នែកទី ៦។

សម្ងាត់ទាំងអស់ នៅក្នុងរយៈពេល ២០ឆ្នាំ បន្ទាប់ពីការបិទបញ្ចប់ អ.វ.ត.ក និងគួរតែធ្វើការពិនិត្យឡើងវិញលើសម្ភារ "សម្ងាត់បំផុត"ទាំងអស់ ក្នុងរយៈពេល ២០ឆ្នាំ (ឬ ៥០ឆ្នាំ ប្រសិនបើមានមូលហេតុច្បាប់បង្ខំជាយុត្តិកម្មក្នុងការបន្តនូវភាពសម្ងាត់) ក្រោយការបិទបញ្ចប់ អ.វ.ត.ក៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោក Fergal GAYNOR**<br>សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង) | ឌុយប្លាំង, អៀរឡង់ | [signature] |